ឆ្នាំទី២ លេខ០១០ ចេញផ្សាយប្រចាំខែឧសភា ឆ្នាំ២០១២

# ព្រឹត្តិបត្រការងារ
# Labour Bulletin

ជាស្ពានរបស់រាជរដ្ឋាភិបាលឆ្ពោះទៅកាន់ ♦ ការងារ ♦ កម្លាំងពលកម្ម ♦ ព័ត៌មានទីផ្សារការងារ ⊕ Government gateway to ♦ Job ♦ Workforce ♦ Labour Market Information




រៀបចំ និងបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារជាតិមុខរបរ និងការងារ នៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល


- ជំនាញមូលដ្ឋានគ្រឹះ(ត) [ទំព័រ៦]
- ការពិនិត្យ និងជ្រើសរើសអាជីព ឬការងារដែលសមស្រប [ទំព័រ១]
- ទំនួលខុសត្រូវនៃកិច្ចសន្យាការងារ [ទំព័រ២៧]
- [ទំព័រ៣១] ព័ត៌មានទីផ្សារការងារនៅកម្ពុជា
- [ទំព័រ៣៦] មុខរបរទាំងដប់ដែលមានតម្រូវការខ្លាំង...
- [ទំព័រ៤៧] ព័ត៌មានជ្រើសរើសបុគ្គលិក

ទីភ្នាក់ងារជាតិមុខរបរ និងការងារ

ព្រឹត្តិបត្រការងារ

# មាតិកា


| | ទំព័រ |
|---|---|
| ◈ **ព័ត៌មាន និងសកម្មភាព** | ១ |
| ➢ សកម្មភាពថ្មីៗពាក់ព័ន្ធនឹងវិស័យការងារ .......... | ១ |
| ◈ **មគ្គទេសក៍អាជីព** | ៦ |
| ➢ ជំនាញមូលដ្ឋានគ្រឹះ (Fundamental Skills) (ត) | ៦ |
| ⭘ *ជំនាញ ៧៖ ការធ្វើសេចក្តីសម្រេចចិត្ត [ទំព័រ ៦]* ⭘ *ជំនាញ៨៖ ការដោះស្រាយបញ្ហា [ទំព័រ ៨]* | ៦ |
| ➢ ការពិនិត្យ និងជ្រើសរើសអាជីព ឬការងារដែលសមស្រប | ១១ |
| ⭘ *អ្នកបង្កើតគំរូម៉ូតសម្រាប់ឧស្សាហកម្ម (Industrial Designers) [ទំព័រ ១១]* ⭘ *អ្នកបង្កើតកម្មវិធីកុំព្យូទ័រ (Software Designers) [ទំព័រ ១២]* ⭘ *អ្នកផ្សាយកម្មវិធីវិទ្យុ និងទូរទស្សន៍(Radio and Television Announcers) [ទំព័រ ១៤]* ⭘ *វេជ្ជបណ្ឌិតផ្នែកការវះកាត់(Surgeons) [ទំព័រ ១៥]* ⭘ *ឱសថការី (Pharmacists) [ទំព័រ១៧ ]* | ១១ |
| ➢ ការរៀបចំមូលដ្ឋានគ្រឹះក្នុងការស្វែងរកការងារធ្វើ | |
| ⭘ *ការចរចាប្រាក់បៀវត្ស និងការសម្រេចចិត្តទទួលយកការងារ* | ១៩ |
| ➢ ការណែនាំអំពីវិធីបំពេញការងារ | |
| ⭘ *ការស្វែងយល់អំពីតថភាពនៅក្នុងកន្លែងការងារ* | ២៣ |
| ◈ **លិខិតបទដ្ឋានគតិយុត្តការងារ** | ២៧ |
| ➢ ទំនួលខុសត្រូវនៃកិច្ចសន្យាការងារ | ២៧ |
| • ទំនួលខុសត្រូវរបស់និយោជកចំពោះលក្ខខណ្ឌទូទៅនៃការងារ | ២៧ |
| ◈ **ព័ត៌មានទីផ្សារការងារនៅកម្ពុជា** | ៣១ |
| ➢ ទិន្នន័យសំខាន់ៗស្តីពីអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក ......... | ៣១ |
| ◈ **មុខរបរទាំងដប់ដែលមានតម្រូវការខ្លាំងក្នុងទីផ្សារការងារកម្ពុជា** | ៣៦ |
| ➢ *១. កម្មករជំនាញដេរប៉ាក់ [ទំព័រ ៣៧] ២. កម្មករជំនាញអេឡិចត្រូនិច [ទំព័រ ៣៨] ៣. កម្មករក្នុងវិស័យកសិកម្ម [ទំព័រ ៣៩] ៤. សន្តិសុខ [ទំព័រ ៤០] ៥. ជាងអគ្គិសនី [ទំព័រ ៤១] ៦. អ្នកជំនាញផ្នែកលក់ និងទីផ្សារ [ទំព័រ ៤២] ៧. សាស្ត្រាចារ្យ [ទំព័រ ៤៣] ៨. មគ្គុទេស ទេសចរ [ទំព័រ ៤៤] ៩. វិស្វករសំណង់ស៊ីវិល [ទំព័រ ៤៥] ១០. គណនេយ្យករ [ទំព័រ ៤៦]* | |
| ◈ **ព័ត៌មានជ្រើសរើសបុគ្គលិក** | ៤៧ |
| ➢ ព័ត៌មានជ្រើសរើសបុគ្គលិកសម្រាប់ខែឧសភាដែលបានប្រមូលដោយ ទ.ជ.ម.ក | ៤៧ |
| ◈ **ផ្សេងៗ** | |
| ➢ ទំព័រ «កំសាន្ត និងប្រាជ្ញា» | ៥៥ |


❁ចំណងជើងក្របមុខ៖ *សកម្មភាពពាក់ព័ន្ធនឹងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការងារASEAN លើកទី២២នៅវិមានសន្តិភាព*

❁ចំណងជើងក្របក្រោយ៖ *វឌ្ឍនភាពឆ្ពោះទៅកាន់អនាគត*

# ព្រឹត្តិបត្រការងារ


**គណៈគ្រប់គ្រង**

ឯកឧត្តម ពេជ សោភ័ន

ឯកឧត្តម ប៉ុក ប៉ាន់

ឯកឧត្តម ឡៅ ហ៊ីម

ឯកឧត្តម ហេង សួរ

**នាយកគ្រប់គ្រងទូទៅ**

ឯកឧត្តម ហុង ជឿន

**និពន្ធនាយក**

លោក សាម៉េន សុខា

**និពន្ធនាយករង**

លោក ហៃ ហ៊ុនឡេង

លោក សួង សង្ហាវុទ្ធី

លោក ទូច សុផាត

**អាទិនិពន្ធ**

លោក សុកខុន ដារីដ

លោក តាំង ហ៊ាងថារិទ្ធ

លោកស្រី លី វួចចេង

លោក ខាន់ ចិន្តា

លោក តាំង ផេងរិទ្ធី

លោក សុជាតិ កញ្ញារិទ្ធ

មន្ត្រីទីភ្នាក់ងារជាតិមុខរបរ និងការងារ

**នាយកគ្រប់គ្រងការផ្សាយ**

លោក ខេង សុគន្ធា

**នាយកគ្រប់គ្រងការបោះពុម្ព**

លោក គឹម កែវស្មើ

**នាយកគ្រប់គ្រងផ្នែករូបភាព និងកុំព្យូទ័រ**

លោក ផូរ ឧស្សាហ៍រចនា

**អ្នករចនាអត្ថបទ**

កញ្ញា ឈា បញ្ញារី

**អ្នកកែសម្រួលអក្ខរាវិរុទ្ធ**

មន្ត្រី ទីភ្នាក់ងារជាតិមុខរបរ និងការងារ



ព័ត៌មាន និងសកម្មភាព

# សកម្មភាពថ្មីៗពាក់ព័ន្ធនឹងវិស័យការងារ និង ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

## កម្ពុជារៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីការងារអាស៊ាន លើកទី២២

The 22nd ASEAN Labour Ministers Meetings—ALMM



វិមានសន្តិភាព៖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ថ្លែងសុន្ទរកថា ក្នុងឱកាសនៃការបើកកិច្ចប្រជុំរដ្ឋមន្ត្រីការងារអាស៊ាន លើកទី២២ កាលពីថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០១២។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖ កន្លងទៅថ្មីៗនេះ កម្ពុជាបានទទួលរៀបចំក្នុងនាមជាម្ចាស់ផ្ទះនូវកិច្ចប្រជុំដ៏សំខាន់ជាច្រើនរវាងរដ្ឋមន្ត្រីការងារនៃបណ្តាប្រទេសជាសមាជិកអាស៊ានលើកទី ២២ ( 22nd ASEAN Labour Ministers Meetings - ALMM)។ កិច្ចប្រជុំនោះបានប្រារព្ធឡើងជាបន្តបន្ទាប់ចាប់ពីថ្ងៃទី ៣ ដល់ថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១២ ដែលទទួលបានការអញ្ជើញចូលរួមបើកអង្គពិធីក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

សូមបញ្ជាក់ផងដែរថា នៅក្នុងឱកាសនៃកិច្ចប្រជុំ ALMM លើកទី២២ នេះ មានការរៀបចំនូវកិច្ចប្រជុំពិភាក្សាបែបបច្ចេកទេសជាច្រើនប្រភេទដែលប្រព្រឹត្តទៅរវាងបណ្តាប្រទេសដែលជាសមាជិក ASEAN ព្រមទាំងកិច្ចប្រជុំទ្វេភាគីដោយឡែក កិច្ចប្រជុំរបស់មន្ត្រីបច្ចេកទេស និងមន្ត្រីជាន់ខ្ពស់ជាដើម។

### កម្មវិធីសង្ខេបនៃកិច្ចប្រជុំ

- ៣-៥ ឧសភា៖ កិច្ចប្រជុំរបស់គណៈកម្មាធិការអាស៊ានសម្រាប់ការអនុវត្តនូវសេចក្តីប្រកាសរបស់អាស៊ានស្តីពីការគាំពារ និងលើកកម្ពស់ចំពោះសិទ្ធរបស់កម្មករចំណាកស្រុក (ASEAN Committee on the Implementation of the ASEAN Declaration on the Protection and Promotion of the Rights of Migrant Workers—ACMW)។
- ៦-៧ ឧសភា៖ កិច្ចប្រជុំរបស់មន្ត្រីជាន់ខ្ពស់ផ្នែកការងារ លើកទី៨ (The 8th Senior Labour Officials Meeting—SLOM) ស្តីពីការលើកកម្ពស់កិច្ចគាំពារសង្គម និងការអភិវឌ្ឍជំនាញ។



- ៧ ឧសភា៖ កិច្ចប្រជុំស្តីពីគម្រោងការធានារ៉ាប់រងចំពោះនិកម្មភាព និងសេវាការងារ រវាងប្រទេសនៃសមាជិកអាស៊ាន អង្គការពលកម្មអន្តរជាតិ និងប្រទេសជប៉ុន (ASEAN-ILO/Japan Project on Unemployment Insurance and Employment Services—UI)។
- ៧ ឧសភា៖ កិច្ចប្រជុំគណកម្មាធិការសហប្រតិបត្តិការគម្រោង លើកទី៥

តទៅទំព័របន្ទាប់

ស្តីពីកម្មវិធីអាស៊ានផ្តោតលើទំនាក់ទំនងក្នុងវិស័យឧស្សាហកម្មដំណាក់កាលទី ៤ (ASEAN Programme on Industrial Relations —Phase IV) និងគម្រោងផ្តោតទៅលើទំនាក់ទំនងក្នុងវិស័យឧស្សាហកម្មរវាង អាស៊ាន ជាមួយអង្គការពលកម្មអន្តរជាតិ និងជប៉ុន (ASEAN-ILO/Japan Project on Industrial Relations—AIJPIR)។

- ៨ ឧសភា៖ កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ផ្នែកការងារអាស៊ាន+៣ លើកទី១០ (The Tenth ASEAN Plus Three Senior Labour Officials Meeting—SLOM+3) ស្តីពីការលើកកម្ពស់កិច្ចគាំពារសង្គម និងការអភិវឌ្ឍជំនាញ។



- ៩ ឧសភា៖ សន្និសីទធនធានមនុស្សអាស៊ាន លើកទី៣ ស្តីពីការអភិវឌ្ឍជំនាញឆ្ពោះទៅកាន់ការចល័តកាន់តែទូលំទូលាយនៃកម្លាំងពលកម្មដែលមានជំនាញនៅក្នុងបណ្តាប្រទេសអាស៊ាន (The 3rd ASEAN Human Resource Conference—Skill Development Towards a Greater Mobility of Skilled Labour in ASEAN) ។

- ១០ ឧសភា៖ កិច្ចប្រជុំរដ្ឋមន្ត្រីការងារអាស៊ានលើកទី២២ (The 22nd ASEAN Labour Ministers Meeting—ALMM) ស្តីពីការលើកកម្ពស់កិច្ចគាំពារសង្គម និងការអភិវឌ្ឍជំនាញ។




- ១១ ឧសភា៖ កិច្ចប្រជុំរដ្ឋមន្ត្រីការងារអាស៊ាន+៣ លើកទី៧ (The 7th ASEAN Plus Three Labour Ministers Meeting—ALMM+3) ស្តីពីការលើកកម្ពស់កិច្ចគាំពារសង្គម និងការអភិវឌ្ឍជំនាញ។

កិច្ចប្រជុំទាំងអស់ខាងលើបានប្រព្រឹត្តិទៅប្រកបដោយជោគជ័យ និងលទ្ធផលជាផ្លែផ្កាក្នុងស្មារតីយោគយល់ និងសហប្រតិបត្តិការយ៉ាងមហាភារតភាពសមដូចទិសស្លោកដែលបានពោលថា «**អាស៊ានសហគមន៍តែមួយ ជោគវាសនាតែមួយ!**» ដែលនឹងនាំឆ្ពោះទៅដល់ការធ្វើសមាហរណកម្មនៃកម្លាំងពលកម្មទៅក្នុងទីផ្សារការងារអាស៊ាននាឆ្នាំ ២០១៥ ដ៏ខ្លីខាងមុខ៕




សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន (រូបកណ្តាល) និងបណ្តារដ្ឋមន្ត្រីការងារនៃប្រទេសអាស៊ាន + ៣ ក្នុងឱកាសនៃកិច្ចប្រជុំរដ្ឋមន្ត្រីការងារអាស៊ាន លើកទី ២២ នៅវិមានសន្តិភាព កាលពីថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០១២។


តទៅទំព័របន្ទាប់

## NEA និង RULE ធ្វើសិក្ខាសាលាស្តីអំពី "សេវាការងារ និងព័ត៌មានទីផ្សារការងារ"



សាកលវិទ្យាល័យភូមិន្ទ - នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋ-កិច្ច (RULE)៖ កាលពីថ្ងៃទី២៥-២៦ ខែមេសា ឆ្នាំ២០១២ កន្លងទៅនេះ មជ្ឈមណ្ឌលការងាររាជធានីភ្នំពេញ ក្នុងកិច្ចសហការជាមួយក្រុមការងារមគ្គុទេសក៍អាជីព បានចុះធ្វើសិក្ខាសាលាផ្សព្វផ្សាយស្តីអំពី «សេវាការងារ និងព័ត៌មានទីផ្សារការងារ» និង «វិធីសាស្ត្រក្នុងការសរសេរប្រវត្តិរូប និងលិខិតអម» នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច(RULE)។ សិក្ខាសាលានេះបានទាក់ទាញនិស្សិតមកចូលរួមស្តាប់ និងសិក្សាស្វែងយល់មានចំនួន **២៨៧នាក់** (ស្រី **១៥៨នាក់**)។

លទ្ធផលដែលទទួលបានរួមមាន៖ បានចែកទម្រង់ចុះឈ្មោះអ្នកស្វែងរកការងារធ្វើចំនួន **១២០០សន្លឹក** និងទទួលទម្រង់ដែលបំពេញរួចបានចំនួន **៣២៤សន្លឹក** ព្រឹត្តិបត្រការងារចំនួន**១០ក្បាល** និងសៀវភៅណែនាំសម្រាប់អ្នកស្វែងរកការងារធ្វើចំនួន **១០ក្បាល**។ លើសពីនេះទៀត បញ្ជររបស់ NEA ក៏បានទាក់ទាញនិស្សិតឱ្យចូលទស្សនាយ៉ាងកុះករដែលមានចំនួនសរុប **១០៤៦នាក់** (ស្រី **៦១៨នាក់**) ផងដែរ៕

## NEA ធ្វើសិក្ខាសាលាមួយទៀតនៅ សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា ( CUP )



NEA នៅតែបន្តអនុវត្តនូវយុទ្ធនាការណ៍ផ្សព្វផ្សាយក្នុងរូបភាពជាសិក្ខាសាលា ដើម្បីពន្យល់ស្តីអំពី"សេវាការងារ និងព័ត៌មានទីផ្សារការងារ" របស់ខ្លួន ដែលធ្វើឡើងកាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១២ នៅឯសាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា (CUP)។ សិក្ខាសាលានេះទាញចំណាប់អារម្មណ៍និស្សិតឱ្យចូលរួមស្តាប់បទបង្ហាញ និងសិក្សាស្វែងយល់ពីការផ្តល់សេវារបស់មជ្ឈមណ្ឌលការងារមានចំនួន **១៩៤នាក់** (ស្រី **១២០នាក់**)។ គោលបំណងនៃសិក្ខាសាលា គឺធ្វើការផ្សព្វផ្សាយអំពីសេវាការងារ ដើម្បីផ្តល់ឱកាសទទួលបានការងារធ្វើជូនដល់និស្សិត។ ជាលទ្ធផល NEA បានចែកខិត្តបណ្ណផ្សព្វផ្សាយចំនួន **២១០សន្លឹក** ព្រឹត្តិបត្រការងារចំនួន **៧ក្បាល** និងទទួលទម្រង់ចុះឈ្មោះអ្នកស្វែងរកការងារធ្វើដែលបំពេញរួចចំនួន **១១៧ទម្រង់** ៕

## របាយការណ៍បូកសរុបការងារប្រចាំខែមេសា និង ទិសដៅអនុវត្តខែបន្តរបស់ ទ.ជ.ម.ក

NEA៖ កាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២ នៅទីស្នាក់ការកណ្តាលរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ បានរៀបចំកិច្ចប្រជុំបូកសរុបការងារប្រចាំខែមេសា និងលើកទិសដៅអនុវត្តបន្តក្នុងខែឧសភាដែលប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម ហុង ជឿន** ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ ដោយមានការចូលរួមពីសំណាក់មន្ត្រីរាជការនៅថ្នាក់កណ្តាលទាំងអស់។ កិច្ចប្រជុំបូកសរុបនេះបានទទួលលទ្ធផលសំខាន់ៗដូចខាងក្រោម៖

- បានរៀបចំបូកសរុបរបាយការណ៍ ស្តីពីផែនការសកម្មភាពសម្រាប់ឆ្នាំ២០១២ ពីគ្រប់ផ្នែក និងគ្រប់ក្រុមការងារទាំងអស់របស់NEA ព្រមទាំងរបាយការណ៍លទ្ធផលការងាររបស់NEA ប្រចាំត្រីមាសទី០១ (ខែមករា-មីនា) ឆ្នាំ២០១២។
- បានទទួលឈ្មោះជនបង្គោលនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានចំនួន ៣៥គ្រឹះស្ថាន និងនៅសល់ចំនួន ០២គ្រឹះស្ថានដែលមិនទាន់បានទទួលឈ្មោះជនបង្គោលនៅឡើយ។
- បានរៀបចំសិក្ខាសាលា និងពិព័រណ៍ចល័តផ្សព្វផ្សាយអំពីសេវាការងារ និងព័ត៌មានទីផ្សារការងាររបស់ NEA ដើម្បីផ្សព្វផ្សាយបង្កើនការយល់ដឹងជាសាធារណៈ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលមានអ្នកចូលរួមចំនួន ១.៣៣៣នាក់។

បន្ទាប់ពីការធ្វើរបាយការណ៍តាមផ្នែក និងក្រុមការងារនីមួយៗរួចមក ឯកឧត្តមប្រធានបានវាយតម្លៃខ្ពស់ចំពោះការអនុវត្តការងារដែលសម្រេចបាននូវលទ្ធផលគួរឱ្យកត់សម្គាល់ និងសំណូមពរឱ្យមន្ត្រីរាជការទាំងអស់បន្តនូវឆន្ទៈពុះពារអនុវត្តការងារឱ្យបានខ្លាំងក្លាថែមទៀត ដើម្បីចូលរួមចំណែកទាំងអស់គ្នាសម្រេចឱ្យបាននូវផែនការអនុវត្តការងារប្រចាំឆ្នាំ២០១២នេះ៕



# វគ្គបណ្តុះបណ្តាលជំនាញក្រោមមូលនិធិពិសេសសម្តេចតេជោនាយករដ្ឋមន្ត្រី

បន្ទាប់ពីបានផ្សព្វផ្សាយសេចក្តីជូនដឹងស្តីពីវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈក្រោមគម្រោង "**មូលនិធិពិសេសរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី**" លេខ ០៧៣/១២ កប/សជណ ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ២០១២ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរួចមក គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ចំនួន ១៦គ្រឹះស្ថាន នៅតាមរាជធានី-ខេត្ត បានធ្វើការជ្រើសរើសសិក្ខាកាមជាក្រុមគោលដៅដូចជា យុវជន យុវនារី និងកម្មករ កម្មការិនីដែលបាត់បង់ និងគ្មានការងារធ្វើ និងកំពុងធ្វើការបណ្តុះបណ្តាលចំនួន ១៦៧វគ្គ ដែលមានសិក្ខាកាមសរុប ចំនួន ៣.៦០០នាក់ ក្នុងនោះផ្នែកបច្ចេកទេស ឧស្សាហកម្ម សេវាកម្ម និងសិប្បកម្មចំនួន ១៤១វគ្គ សិក្ខាកាមសរុបចំនួន ២.៨២០នាក់ និងផ្នែកកសិកម្មចំនួន ២៦វគ្គ សិក្ខាកាមសរុបចំនួន ៧៨០នាក់។ (ស្ថិតិនេះគិតត្រឹម ខែឧសភា ឆ្នាំ២០១២)

## ❖ ផ្នែកឧស្សាហកម្ម បច្ចេកទេស សិប្បកម្ម សេវាកម្ម និងទេសចរណ៍

📖 បណ្តុះបណ្តាលរយៈពេល ៤ខែ លើជំនាញគ្រប់គ្រងគណនេយ្យ និងហិរញ្ញវត្ថុ ទេសចរណ៍ ទីផ្សារ បដិសណ្ឋារកិច្ច កុំព្យូទ័ររដ្ឋបាល កុំព្យូទ័រឌីស្សាញ(រចនារូបភាព) កុំព្យូទ័រគណនេយ្យ ជួសជុលកុំព្យូទ័រ ជួសជុលរថយន្ត ជួសជុលម៉ាស៊ីនធុនតូច ជួសជុលម៉ូតូ ជួសជុលបរិក្ខារត្រជាក់ ជួសជុលបរិក្ខារអគ្គិសនី ជួសជុលអេឡិចត្រូនិច ជួសជុលទូរស័ព្ទដៃ ដំឡើងបណ្តាញអគ្គិសនី ជួសជុលវិទ្យុម៉ាញ៉េ និងទូរទស្សន៍ ជាងផ្សារអគ្គិសនី និងឧស្ម័ន ជាងផ្សារដែកសំណង់ស៊ីវិល ជាងកំបោរ តបណ្តាញទឹក ដំឡើងទូកញ្ចក់អាលុយមីញ៉ូម សិប្បកម្មកែច្នៃផ្តៅ ត្បាញហូល កាត់ដេរសម្លៀកបំពាក់បុរស-នារី កាត់ដេរកែច្នៃម៉ូដ សំអាងការសំអាងកាយ ផាត់មុខ អ៊ុតសក់ និងធ្វើក្រចក កាត់សក់បុរស-នារី បោះពុម្ពលើអាវយឺត-ស្រោមសំបុត្រ កែច្នៃម្ហូបអាហារ ធ្វើម្ហូប ការបង្កើតអាជីវកម្មខ្នាតតូច ។ល។



ជួសជុលម៉ូតូ



ធ្វើនំ



ជួសជុលរថយន្ត


តទៅទំព័របន្ទាប់

## ❖ ផ្នែកកសិកម្ម

📖 បណ្តុះបណ្តាលមានរយៈពេល ១ខែ លើជំនាញ ដាំបន្លែគ្រប់មុខ ធ្វើជីកំប៉ុស្តិ៍ បណ្តុះផ្សិតចំបើង ផ្សិតអំបោះ ធ្វើមេផ្សិត ចិញ្ចឹមជ្រូក មាន់ ទា គោ ក្របី និងចាក់វ៉ាក់សាំង ចិញ្ចឹមត្រី ចិញ្ចឹមចង្រិត ចិញ្ចឹមក្រួច បច្ចេកទេសធ្វើឡឧស្ម័ន ការប្រើប្រាស់ជី និងថ្នាំពុលកសិកម្ម ផលិតចំណី និងបច្ចេកទេសចិញ្ចឹមសត្វ។ល។



**ចិញ្ចឹមមាន់ និងចាក់វ៉ាក់សាំង**



**ចិញ្ចឹមត្រី**



**បណ្តុះផ្សិតចំបើង**



**ដាំបន្លែរួមផ្សំ**




មគ្គុទេសក៍អាជីព

# ជំនាញមូលដ្ឋានគ្រឹះ (ត)

FUNDAMENTAL SKILLS

ជំនាញ ៧

## ការធ្វើសេចក្តីសម្រេចចិត្ត

(Making Decisions)



លទ្ធភាពដែលមានសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តគឺជាជំនាញដ៏ប្រសើរបំផុត។ ប៉ុន្តែ តើធ្វើដូចម្តេចទើបដឹងថាការសម្រេចចិត្តចំពោះកិច្ចការអ្វីមួយមានភាពត្រឹមត្រូវ? ទោះបីជាពេលខ្លះលោក-អ្នកបានជ្រើសរើសដោយខុសឆ្គងចំពោះវត្ថុ ឬជម្រើសអ្វីមួយ ប៉ុន្តែប្រសិនលោក-អ្នកអាចកំណត់អំពីគោលបំណងបានច្បាស់លាស់ ហើយពិនិត្យពិច័យ និងថ្លឹងថ្លែងឱ្យបានល្អិតល្អន់នូវរាល់ជម្រើសទាំងអស់នោះ លោក-អ្នកនៅតែមានឱកាស និងលទ្ធភាពល្អប្រសើរក្នុងការធ្វើសេចក្តីសម្រេចចិត្តជាក់ជាពុំខាន។ ដើម្បីអាចក្លាយខ្លួនជាមនុស្ស ដែលពូកែក្នុងការធ្វើសេចក្តីសម្រេចចិត្ត លោក-អ្នកត្រូវតែពុះពារសម្រេចឱ្យបាននូវទង្វើនានាដូចដែលបានរិះគិតក្នុងចិត្ត ឬផែនការរួចហើយ។



ជំនាញក្នុងការធ្វើសេចក្តីសម្រេចចិត្ត គឺរួមបញ្ចូលទៅដោយលទ្ធភាពមួយចំនួនដូចជា៖

- ការកំណត់អំពីគោលបំណង និងបញ្ហាប្រឈមនានា។
- ការសម្រេចចិត្តចំពោះជម្រើសនានាដែលមានចំពោះមុខ។
- ការគិតពិចារណាអំពីផលវិបាក ផលប៉ះពាល់ គ្រោះថ្នាក់។
- ការវាយតម្លៃ និងជ្រើសរើសនូវជម្រើសដ៏ល្អបំផុត។

*អត្ថបទដកស្រង់ និងប្រែសម្រួលដោយ **ហៃ ហ៊ុនឡេង**។ សម្រាប់ព័ត៌មានបន្ថែមសូមអញ្ជើញអានឯកសារឈ្មោះ Younger Person's Career Skills Handbook. JIST Publishing, 2006. ដែលមានតម្កល់នៅក្នុង «**បណ្ណាល័យការងារ**» របស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ។*


តទៅទំព័របន្ទាប់

## អាជីពដែលត្រូវការជំនាញនៃការធ្វើសេចក្ដីសម្រេចចិត្ត

បុគ្គលិក និយោជិតទាំងអស់នឹងបំពេញកិច្ចការរបស់ខ្លួនបានល្អប្រសើរ កាលណាពួកគេមានជំនាញក្នុងការធ្វើសេចក្ដីសម្រេចចិត្ត។ ទោះជាយ៉ាងដូច្នោះក្ដី គេសង្កេតឃើញថា ការងារជាលក្ខណៈអាជីពមួយចំនួនត្រូវការជំនាញបែបនេះជាខ្លាំង មានជាអាទិ៍៖

| | |
|---|---|
| ✪ ចៅក្រម | ✪ អ្នកតុបតែងបន្ទប់ ឬអគារ |
| ✪ ភ្នាក់ងារផ្នែកទិញ-លក់ | ✪ គិលានុបដ្ឋាក |
| ✪ ប្រធានគ្រប់គ្រងហិរញ្ញវត្ថុ | ✪ អ្នកមើលថែទាំកុមារ |
| ✪ នាយទាហ៊ាន | ✪ អ្នកគ្រប់គ្រងការអប់រំ |
| ✪ គ្រូបង្វឹក | ✪ ប្រធានគ្រប់គ្រងការសាងសង់ |



## ហេតុអ្វីនិយោជកត្រូវការជំនាញបែបនេះ?

នៅក្នុងបរិយាកាសបំពេញការងាររាល់ថ្ងៃ បុគ្គលិកទាំងអស់តែងត្រូវបានជំរុញ ឬតម្រូវឱ្យធ្វើនូវសេចក្ដីសម្រេចចិត្តចំពោះកិច្ចការផ្សេងៗ ទោះតូច ឬធំ ធ្ងន់ ឬស្រាលជាច្រើនរាប់មិនអស់។ អ្នកទំនងជាត្រូវធ្វើការសម្រេចចិត្តដ៏សំខាន់ចំពោះយុទ្ធសាស្ត្រជំនួញក្នុងក្រុមហ៊ុន។ ប្រហែល អ្នកគឺជាមនុស្ស ដែលត្រូវសម្រេចចិត្តជ្រើសរើសទិញវត្ថុប្រើប្រាស់សម្រាប់ការិយាល័យរបស់ក្រុមហ៊ុន។ម្យ៉ាងទៀត អ្នកទំនងជាត្រូវសម្រេចចិត្តចំពោះតម្លៃ ឬការចំណាយផ្សេងៗក្នុងផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុន ។ល។

ទោះបីជា លោកអ្នកស្ថិតនៅក្នុងស្ថានភាពនៃការសម្រេចចិត្តបែបណាក៏ដោយ ការសម្រេចចិត្តបានលឿនទាន់ពេលវេលាដោយមិនបង្អែបង្អង់ គឺជាប្រការដ៏មានសារសំខាន់បំផុត។ មនុស្សខ្លះ មានភាពស្ទាក់ស្ទើរក្នុងចិត្តចំពោះការជ្រើសរើស ឬសម្រេចកិច្ចការអ្វីមួយ ដោយហេតុថា ពួកគេមិនអាចថ្លឹងថ្លែងអំពីគុណសម្បត្តិ និងគុណវិបត្តិរបស់កិច្ចការ។ នៅក្នុងបរិបទការងារ កាលណានិយោជិតម្នាក់មិនមានលទ្ធ-ភាពគ្រប់គ្រាន់ក្នុងការសម្រេចចិត្តចំពោះរឿងអ្វីមួយ នោះចាត់ទុកថាជាការបាត់បង់ឱកាស ឬផលចំណេញរបស់ក្រុមហ៊ុន។

ផ្ទុយទៅវិញ បុគ្គលណាដែលមានការតាំងចិត្ត និងហ៊ានធ្វើសេចក្ដីសម្រេចចិត្តបានលឿន និងទាន់ពេលវេលាប្រកបដោយទំនុកចិត្ត នោះចាត់ទុកថាជាមនុស្សដែលមានសមត្ថភាព និងអាចអភិវឌ្ឍអាជីពរបស់គេបានដោយឆាប់រហ័សក្នុងទិសដៅវិជ្ជមាន។ មិនតែប៉ុណ្ណោះ ពួកគេនឹងទទួលបានការជឿទុកចិត្ត ហើយត្រូវបានផ្ដល់ការងារ និងឱកាស ឱ្យបន្ថែមទៀតពីសំណាក់ប្រធានគ្រប់គ្រង។



អាស្រ័យហេតុនេះ គេសង្កេតឃើញថា ប្រធានគ្រប់គ្រង និងអ្នកដឹកនាំភាគច្រើនគឺជាបុគ្គលដែលមានភាពឈ្លាសវៃ និងពូកែនៅក្នុងការធ្វើសេចក្ដីសម្រេចចិត្តស្ទើរគ្រប់កិច្ចការ និងស្ថានភាពទាំងអស់ដែលជួបប្រទះក្នុងពេលបំពេញការងារ។

ការធ្វើសេចក្ដីសម្រេចចិត្តមានន័យថា ជាការហ៊ានប្រថុយ និងទទួលយកនូវបញ្ហាប្រឈម ឬផលវិបាកនានា ប៉ុន្តែ ផលវិបាកទាំងនោះត្រូវជាកិច្ចការដែលអាចដឹងមុន។ មានន័យថា អ្នកត្រូវប្រមូលនូវព័ត៌មាន ទិន្នន័យ និងជម្រើសឱ្យបានច្រើន រួចហើយសឹមធ្វើការសម្រេចចិត្តប្រកបដោយភាពវាងវៃ និងពូកែបំផុត។ ជម្មតា អ្នកមានឱកាសយ៉ាងច្រើនក្នុងការធ្វើនូវសេចក្ដីសម្រេចចិត្តនៅក្នុងជីវិតប្រចាំថ្ងៃរបស់អ្នក ហេតុនេះ សូមសាកល្បងប្រើប្រាស់នូវឱកាសទាំងនោះដើម្បីហាត់រៀនជំនាញក្នុងការសម្រេចចិត្តចាប់ពីឥឡូវនេះតទៅ។ តាមរយៈវិធីបែបនេះ អ្នកនឹងមានឱកាសក្នុងការទទួលបាននូវជំនាញដ៏ល្អមួយសម្រាប់ការងារនាពេលអនាគត។



## ការបង្កើតជំនាញនៃការធ្វើសេចក្ដីសម្រេចចិត្ត

លោក-អ្នកអាចបង្កើតជំនាញក្នុងការសម្រេចចិត្តតាមរយៈការទាញយកផលប្រយោជន៍អំពីការសិក្សា និងក្នុងសកម្មភាព ឬឱកាសផ្សេងៗ៖

### ការបង្កើនជំនាញតាមរយៈការអប់រំ៖

- សិក្សាមុខវិជ្ជាជំនួញ និងគ្រប់គ្រងដើម្បីស្វែងយល់ពីវិធីសាស្ត្រ និងបច្ចេកទេសដែលពាណិជ្ជករ ឬអ្នកជំនួញនិយមប្រើប្រាស់ក្នុងការសម្រេចចិត្តចំពោះកិច្ចការរបស់ពួកគេ។
- សិក្សាមុខវិជ្ជាប្រវត្តិសាស្ត្រ ដើម្បីស្វែងយល់អំពីសេចក្ដីសម្រេចចិត្តដ៏មានសារសំខាន់នានា ព្រមទាំងសេចក្ដីសម្រេចចិត្តណាខ្លះដែលមិនទទួលបានជោគជ័យ។



### ការបង្កើនជំនាញតាមរយៈសកម្មភាពផ្សេងៗ៖

- ប្រកាន់យកតួនាទីជាប្រធាន ឬអ្នកដឹកនាំក្នុងក្រុមការងារ ឬក្លឹបដែលតម្រូវឱ្យអ្នកធ្វើសេចក្ដីសម្រេចចិត្តចំពោះក្រុម ឬជំនួសសមាជិក ដូចជាការសម្រេចចិត្តចំពោះការចំណាយថវិកា និងសកម្មភាពដែលត្រូវអនុវត្តឱ្យបានជោគជ័យ។
- នៅក្នុងខណៈពេលដែលលោក-អ្នកជួបប្រឈមជាមួយស្ថានភាពតានតឹង គួរតែចំណាយពេលវេលាដើម្បីសិក្សាវិភាគអំពីស្ថានភាពពិនិត្យថ្លឹងថ្លែងអំពីគុណ និងទោស ព្រមទាំងវាយតម្លៃចំពោះវិធី ឬជម្រើសផ្សេងទៀតដែលត្រូវប្រើជាជំនួស។
- ប្រសិនសេចក្ដីសម្រេចចិត្តចំពោះកិច្ចការអ្វីមួយមិនអាចទទួលបានជោគជ័យដូចក្ដីប្រាថ្នា អ្នកគួរសញ្ជឹងគិតឡើងវិញថា តើការសម្រេចចិត្តបែបណាដែលអាចទទួលបានលទ្ធផលប្រសើរជាងនេះ? បន្ទាប់មករក្សាទុកនូវគំនិតបែបនោះដើម្បីប្រើប្រាស់ជាជំនួយដល់ការសម្រេចចិត្តនាពេលក្រោយៗទៀត។

## ជំនាញ ៨ ការដោះស្រាយបញ្ហា

(Solving Problems)



«បញ្ហា» គឺជាតថភាពមួយនៃជីវិតរស់នៅប្រចាំថ្ងៃរបស់មនុស្សគ្រប់ៗគ្នា។ បញ្ហានឹងកើតមានឡើងកាលណាកិច្ចការ ឬគោលបំណងអ្វីមួយមិនបានប្រព្រឹត្តទៅតាមលក្ខខ័ណ្ឌ និងការគ្រោងទុករបស់នរណាម្នាក់។ ហេតុដូច្នេះ លទ្ធភាពនៅក្នុងការដោះស្រាយបញ្ហា និងបន្តកិច្ចការឱ្យមាននិរន្តរភាព គឺជាកត្តាដ៏សំខាន់បំផុតក្នុងការបំពេញការងារ និងនៅក្នុងជីវិត។

ជំហានដំបូងបំផុតសម្រាប់ការដោះស្រាយបញ្ហា គឺជាការទទួលស្គាល់ដោយខ្លួនឯងថាអ្នកមានបញ្ហា។ អ្នកត្រូវមើលឱ្យឃើញ និងបែងចែកឱ្យបានច្បាស់លាស់រវាងអ្វីដែលកំពុងកើតឡើង និងអ្វីដែលគួរតែកើតឡើង។


តទៅទំព័របន្ទាប់

*ជំនាញក្នុងការដោះស្រាយបញ្ហារួមបញ្ចូលនូវលទ្ធ - ភាពសំខាន់ៗមួយចំនួន ដូចជា៖*

- កំណត់អំពីហេតុផលសមស្របសម្រាប់ដោះស្រាយបញ្ហា។
- រិះគិតអំពីផែនការសកម្មភាពសម្រាប់ដោះស្រាយបញ្ហា ព្រមទាំងអនុវត្តនូវផែនការនោះ។
- កំណត់ក្នុងចិត្តអំពីការប្រព្រឹត្តទៅនៃផែនការដែលត្រូវអនុវត្ត។
- ផ្លាស់ប្តូរផែនការសកម្មភាពដើម្បីសម្របសម្រួលទៅនឹងដំណើរការនៃការបង្កើនប្រសិទ្ធិភាពនៃលទ្ធផល។




## អាជីពដែលត្រូវការជំនាញក្នុងការដោះស្រាយបញ្ហា

- មេធាវី
- ប៉ូលីស
- អ្នកបច្ចេកទេសមេកានិក
- អ្នកបច្ចេកទេសកុំព្យូទ័រ
- អ្នកគ្រប់គ្រងសណ្ឋាគារ
- បុគ្គលិកផ្នែកសេវាអតិថិជន
- អ្នកផ្តល់ការប្រឹក្សាយោបល់
- វិស្វករ
- ជាងជួលជុល
- អ្នកមើលថែទាំកុមារ

## ហេតុអ្វីនិយោជកត្រូវការជំនាញបែបនេះ?

*នៅក្នុងការបំពេញការងារលោក-អ្នកត្រូវការពឹងផ្អែកទៅលើកិច្ចការជាច្រើនដែលប្រព្រឹត្តទៅដោយត្រឹមត្រូវ និងរលូន ឧទាហរណ៍ បុគ្គលិកទាំងអស់តែងព្យាយាមចៀសវាងឱ្យខាងតែបាននូវរាល់កំហុសនានា ឧបករណ៍ប្រើប្រាស់ត្រូវដំណើរការឱ្យបានដូចការរំពឹងគិត ការបញ្ជូនរបស់បញ្ញើឱ្យបានទាន់ពេលវេលាកំណត់ ជាដើម។ ប៉ុន្តែ ផែនការ និងការគ្រោងទុកមិនសុទ្ធតែប្រព្រឹត្តទៅជាប្រក្រតីនោះទេ។ នៅពេលដែលម៉ាស៊ីនគាំងមិនដំណើរការ ការបញ្ជូនរបស់មិនគោរពតាមពេលវេលា ម៉ាស៊ីនកុំព្យូទ័រខូច ។ល។ ទាំងនេះសុទ្ធជាសញ្ញាណនៃបញ្ហាដែលអាចកើតមានឡើងដោយថាហេតុនៅក្នុងប្រតិបត្តិការការងារ គឺពេលនោះហើយដែលអ្នកជួបប្រទះនូវបញ្ហា។*

*ប្រសិនបើ អ្នកពូកែក្នុងការកំណត់អំពីបញ្ហា ដោយរកឱ្យឃើញនូវមូលហេតុដែលបង្ក ហើយរកវិធី ឬផែនការសកម្មភាពដើម្បីដោះស្រាយបញ្ហា អ្នកនឹងមានលទ្ធភាពអាចសម្រេចកិច្ចការដោយជោគជ័យ។ ផ្ទុយទៅវិញ ប្រសិនអ្នកមិនអាចដោះស្រាយបញ្ហាបានទេនោះ អ្នកអាចត្រូវបញ្ឈប់ពីការងារ ឬអនុញ្ញាតឱ្យបំពេញតែការងារណាដែលងាយៗ។*

*គួរកត់សម្គាល់ថា គ្រប់ការផ្លាស់ប្តូរ ឬប្រែប្រួលនៅក្នុងកន្លែងការងារមិនមែនសុទ្ធតែជាបញ្ហានោះទេ។ នៅពេលខ្លះអ្នកត្រូវតែចេះសម្របខ្លួនជាជាងការដោះស្រាយបញ្ហា។ ប៉ុន្តែនៅពេលដែលស្ថានការណ៍ប្រែទៅជាមានបញ្ហា អ្នកត្រូវចេះសិក្សាពិនិត្យដើម្បីរកឱ្យឃើញនូវឫសគល់នៃបញ្ហា បន្ទាប់មកព្យាយាមរកវិធីល្អៗដើម្បីកែប្រែស្ថានការណ៍ឱ្យបានប្រសើរ។ ធម្មតា នៅក្នុងការបំពេញការងារ និយោជកតែងតែរំពឹងចង់បានបុគ្គលិកណា ដែលមានលទ្ធភាពដោះស្រាយបញ្ហាបានដោយខ្លួនឯង ដោយពុំចាំបាច់មានការជ្រោមជ្រែងច្រើន។*

តទៅទំព័របន្ទាប់

# ការបង្កើតជំនាញនៃការដោះស្រាយបញ្ហា

*តើលោក-អ្នកកំពុងតែព្យាយាមរិះរកវិធីក្នុងការដោះស្រាយបញ្ហានានានៅក្នុងជីវិត ឬការសិក្សាមែនដែរឬទេ? ឬក៏ លោក-អ្នកកំពុងតែគេចវេះតាមរយៈការបោះបង់ចោលនូវការដោះស្រាយបញ្ហាឱ្យទៅអ្នកដទៃធ្វើជំនួស។ កាលណាលោក-អ្នកកាន់តែប្រឈមទៅនឹងការដោះស្រាយបញ្ហាដែលមានចំពោះមុខ ខណៈនោះលោក-អ្នកនឹងទទួលបានបទពិសោធន៍ ឬជំនាញទាក់ទងនឹងការដោះស្រាយបញ្ហា។*

*លោក-អ្នកអាចបង្កើត និងបង្កើនជំនាញនេះតាមរយៈវិធីផ្សេងៗ ដូចជា៖*

## ○ ការបង្កើនជំនាញតាមរយៈការអប់រំ៖

- រៀនមុខវិជ្ជាគណិតវិទ្យា ដើម្បីស្វែងយល់ពីវិធីក្នុងការដោះស្រាយបញ្ហាតាមក្បួនតក្កវិជ្ជាផ្សេងៗ។
- ធ្វើអំនានអំពីវិធីក្នុងការគ្រប់គ្រងពាណិជ្ជកម្ម ដើម្បីសិក្សាពីវិធីដែលទទួលបានជោគជ័យក្នុងការដោះស្រាយបញ្ហា។
- សាកសួរទៅកាន់លោកគ្រូ ឬសាស្ត្រាចារ្យរបស់អ្នកនូវឧទាហរណ៍នានាដែលបរិយាយអំពីការដោះស្រាយបញ្ហា។

## ○ ការបង្កើនជំនាញតាមរយៈសកម្មភាពផ្សេងៗ៖

- គិតអំពីផែនការ និងសកម្មភាពដើម្បីកែតម្រូវបញ្ហានានាដែលកើតមាននៅក្នុងជីវិតរបស់អ្នកចាប់ពីពេលឥឡូវនេះតទៅ។
- កំណត់អំពីបញ្ហាដែលកើតមានជុំវិញពិភពលោកនាពេលបច្ចុប្បន្ន ដូចជា បញ្ហាសង្គ្រាម បញ្ហានៃការផលិតឱសថសម្រាប់ព្យាបាលជម្ងឺដែលពិបាកព្យាបាល ឬមិនអាចព្យាបាលបាន។
- លើកជាសំណើរទៅកាន់មនុស្សផ្សេងៗ អំពីបញ្ហាដែលបំរុងកើតមានឡើង តើពួកគេមានវិធី និងអាចដោះស្រាយបានតាមវិធីណាខ្លះ។ បន្ទាប់មក ពិនិត្យមើលទៅលើគំនិត និងយោបល់ដែលផ្តល់ដោយអ្នកទាំងនោះ តើយោបល់ណាមួយល្អជាងគេ តើគំនិតពីរ ឬច្រើនអាចរួមបញ្ចូលគ្នាដើម្បីដោះស្រាយបញ្ហានោះបានដែរឬទេ ប្រសិនបើគំនិតនីមួយៗប្រើប្រាស់វិធីផ្សេងៗគ្នា?



សូមប្រិយមិត្ត និងមិត្តអ្នកអានរង់ចាំអានក្នុងការផ្សាយលេខក្រោយ

ស្តីពីជំនាញមូលដ្ឋានផ្សេងៗទៀត ដោយមេត្រី!



ការពិចារណាអំពីការងារជាអាជីព

# ការពិនិត្យ និង ជ្រើសរើស អាជីព ឬ ការងារដែលសមស្រប

## អ្នកបង្កើតគំរូម៉ូតសម្រាប់ឧស្សាហកម្ម

( Industrial Designers )

**សង្ខេបអំពីជំនាញ**

**អ្នកបង្កើតគំរូម៉ូតសម្រាប់ឧស្សាហកម្មធ្វើការងារ៖**

- ប្រាស្រ័យទាក់ទងផ្នែកគំនិត
- បង្កើត ឬបង្កើនប្រព័ន្ធដំណើរការ
- វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន

**ជំនាញដែលត្រូវការប្រើ៖**

- ការគិតប្រកបដោយភាពច្នៃប្រឌិត
- គណិតវិទ្យា
- ការដោះស្រាយបញ្ហា

## តើអ្នកបង្កើតគំរូម៉ូតសម្រាប់ឧស្សាហកម្មបំពេញកិច្ចការអ្វីខ្លះ?

អ្នកបង្កើតគំរូម៉ូតសម្រាប់ឧស្សាហកម្ម គឺជាផ្នែកមួយដ៏មានសារសំខាន់នៅក្នុងដំណើរការផលិត។ ពួកគេបង្កើតគំរូម៉ូតសម្រាប់សម្ភារថ្មីៗ និងកែច្នៃគំរូដែលមានស្រាប់ឱ្យកាន់តែមានភាពប្រសើរឡើងតាមរយៈរូបរាង តួនាទីក្នុងការប្រើប្រាស់ ប្រសិទ្ធភាព និងភាពងាយស្រួល។ អ្នកបង្កើតគំរូម៉ូតភាគច្រើនបានផ្តោតជាពិសេសទៅលើការបង្កើតនូវផលិតផលប្រភេទអ្វីមួយ ដូចជាឧបករណ៍ប្រើប្រាស់នៅក្នុងផ្ទះ រថយន្ត និងគ្រឿងសង្ហារឹម ជាដើម។ អ្នកខ្លះធ្វើការជាលក្ខណៈឯកជនដោយខ្លួនឯង ឯខ្លះទៀតបម្រើការនៅក្នុងរោងចក្រ ឬសហគ្រាស។

អ្នកបង្កើតគំរូម៉ូតក្នុងវិស័យឧស្សាហកម្មច្រើនធ្វើការជាផ្នែកមួយក្នុងក្រុមអភិវឌ្ឍផលិតផល ដែលព្យាយាមគិតអំពីមធ្យោបាយប្លែកៗក្នុងការធ្វើឱ្យផលិតផលថ្មីៗមានភាពទាក់ - ទាញពីសំណាក់អតិថិជន ឬអ្នកប្រើប្រាស់។ នៅក្នុងកិច្ចការ

---

អត្ថបទដកស្រង់ និងប្រែសម្រួលចេញពីឯកសារ Career Discovery Encyclopedia. Infobase Publishing. Seven Edition, 2009. ដោយ ហៃ ហ៊ុនឡេង។

នេះ ពួកគេត្រូវការគូរនូវគំនូរព្រាងជាច្រើនលើកច្រើនសារ ដើម្បីបង្កើត និងកែសម្រួលនូវរូបរាងរបស់វត្ថុបង្កើតថ្មីឱ្យមានភាពប្រសើរ។ ការគូរអាចជាគំនូរដោយដៃ ឬប្រើកុំព្យូទ័រ និងកម្មវិធីប្លែកៗ។ បន្ទាប់ពីគូរគំនូរព្រាងរួចរាល់ ពួកគេនឹងធ្វើការវាស់វែងនូវចំណុចលម្អិតៗរបស់វត្ថុ ឬឧបករណ៍ ដើម្បីកំណត់ពីលក្ខណៈរូប ធាតុផ្សំ សម្ភារសម្រាប់ផលិត ការប្រើប្រាស់ពណ៌ និងសារធាតុផ្សេងៗជាច្រើនទៀត។ បន្ទាប់មកទៀត គំនូរព្រាង ខ្នាតផ្ទាស់ និងកិនភាគទាំងអស់នឹងត្រូវបញ្ជូនទៅកាន់វិស្វករ ដើម្បីធ្វើការសិក្សាបង្កើតឱ្យចេញជារូបរាងពិត។

ក្នុងករណីខ្លះវិស្វករទទួលបង្កើតនូវឧបករណ៍ទៅតាមគំនូរព្រាង រួចហើយធ្វើការសាកល្បងអំពីដំណើរការរបស់ផលិតផល កម្លាំង ភាពធន់ និងកត្តាផ្សេងៗទៀត ដើម្បីធានាឱ្យបានច្បាស់លាស់ថាផលិតផលថ្មីមានដំណើរការដោយល្អទៅតាមការគ្រោងទុក មានសុវត្ថិភាព និងគោរពតាមបទដ្ឋានរបស់ឧស្សាហកម្ម។

## ការអប់រំ និងការបណ្តុះបណ្តាល

ប្រសិន អ្នកមានបំណងក្លាយខ្លួនជាអ្នកបង្កើតគំរូម៉ូតសម្រាប់វិស័យឧស្សាហកម្ម អ្នកគួរចាប់ផ្តើមសិក្សាមុខវិជ្ជាពាក់ព័ន្ធមួយចំនួនឱ្យបានច្រើន ដូចជា សិល្បៈគំនូរ និងសិល្បៈដទៃទៀត កុំព្យូទ័រក្រាហ្វិក នោះទើបជាការប្រសើរ។ បន្ថែមលើនេះ អ្នកត្រូវសិក្សាមុខវិជ្ជាការបង្កើតគំរូម៉ូតក្នុងវិស័យឧស្សាហកម្ម។ ជំនាញប្រភេទនេះអាចសិក្សានៅតាមសាលាបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ វិទ្យាស្ថានបច្ចេកទេស និងសាលាសិល្បៈ ជាដើម។ ការសិក្សាមុខវិជ្ជានេះតម្រូវឱ្យសិស្ស និស្សិតហាត់គូរនៅលើក្រដាស និងគូរជាគំនូរ 3D នៅក្នុងកុំព្យូទ័រ។

## គួរយល់ដឹង !

✦ មុខវិជ្ជាសិក្សាក្នុងសាលាៈ

សិល្បៈ វិទ្យាសាស្ត្រកុំព្យូទ័រ និងគណិតវិទ្យា

✦ កម្រិតអប់រំទាបបំផុតៈ

បរិញ្ញាបត្រ

✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នាៈ

ស្ថាបត្យករ

វិស្វករអគ្គិសនី និងអេឡិចត្រូនិក

នាយកផ្នែកសិល្បៈ និង

អ្នកបច្ចេកទេសគំនូរក្រាហ្វិក ជាដើម។

## អ្នកបង្កើតកម្មវិធីកុំព្យូទ័រ

( Software Designers )

សង្ខេបអំពីជំនាញ

អ្នកបង្កើតកម្មវិធីកុំព្យូទ័រធ្វើការងារៈ

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត

✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន

✦ ជ្រើសរើស និងប្រើប្រាស់ឧបករណ៍ ឬបច្ចេកទេស

ជំនាញដែលត្រូវការប្រើៈ

✦ ការគិតប្រកបដោយភាពច្នៃប្រឌិត

✦ គណិតវិទ្យា

✦ ការដោះស្រាយបញ្ហា

## តើអ្នកបង្កើតកម្មវិធីកុំព្យូទ័របំពេញកិច្ចការអ្វីខ្លះ?

គ្រប់កុំព្យូទ័រទាំងអស់ កាលណាមិនមានបញ្ចូលកម្មវិធី នោះគេមិនអាចប្រើប្រាស់វាបានទេ។ កម្មវិធីកុំព្យូទ័រ គឺជាប្រព័ន្ធផ្ដុំដោយលេខកូដដែលសម្រាប់ចង្អុលបង្ហាញ និងបញ្ជាឱ្យកុំព្យូទ័រមានដំណើរការ។ កម្មវិធីនីមួយៗត្រូវការតម្លើង (Install) ដោយឡែកៗពីគ្នាទៅតាមតម្រូវការរបស់អ្នកប្រើប្រាស់ ដូចជា កម្មវិធីហ្គេម កម្មវិធីវាយអត្ថបទ និងកម្មវិធីសម្រាប់ធ្វើតារាង ជាដើម។ ក្រៅពីនេះ កម្មវិធីខ្លះទៀតក៏ត្រូវបានគេបង្កើតឡើងជាពិសេសសម្រាប់ការប្រើនៅក្នុងកិច្ចការជំនួញ ឬវិស័យអ្វីមួយផងដែរ។

នៅក្នុងការបង្កើតកម្មវិធីមួយ អ្នកបច្ចេកទេសត្រូវការរិះគិតយ៉ាងម៉ត់ចត់អំពីតួនាទី ដំណើរការ និងរូបលក្ខណៈរបស់កម្មវិធីនៅពេលប្រើប្រាស់។ អ្នកបង្កើតកម្មវិធីពិនិត្យ និងសម្រេចជាបឋមទៅលើកម្មវិធីបែបណាដែលគួរផលិត ឬបង្កើតបាន ឧទាហរណ៍ កម្មវិធិបង្កើតតារាង ការគ្រប់គ្រងបញ្ជីចំណូល និងចំណាយ ជាដើម។ នៅក្នុងការធ្វើកម្មវិធីទាំងនេះអ្នកបង្កើតកម្មវិធីត្រូវសម្រេចថាមាតិកា និងរូបបែបណាដែលគួរប្រើ ហើយរូបរាងរបស់កម្មវិធីគួរមានសភាពបែបណាដែលអាចបម្រើឱ្យផ្នែកសោភណភាព និងមុខងារនៅក្នុងការប្រើប្រាស់។

អ្នកបង្កើតកម្មវិធីខ្លះមានភារៈរៀបចំធ្វើកម្មវិធីប្រើប្រាស់ជាពិសេសមួយសម្រាប់ក្រុមហ៊ុន និងតម្រូវការជាក់លាក់មួយដើម្បីសម្រួលដល់ការគ្រប់គ្រងនៅក្នុងក្រុមហ៊ុន ឬស្ថាប័ននោះ។ ក្រុមហ៊ុន ឬស្ថាប័នខ្លះមានទំហំការងារ និងការគ្រប់គ្រងធំធេង ដែលតម្រូវឱ្យបង្កើតកម្មវិធីប្រើប្រាស់ផ្ទាល់សម្រាប់កុំព្យូទ័ររបស់ពួកគេ។ ក្នុងករណីនេះ អ្នកបង្កើតកម្មវិធីត្រូវសិក្សាអំពីប្រព័ន្ធកុំព្យូទ័រដែលមាននៅក្នុងស្ថាប័ន ដើម្បីសម្របសម្រួលបង្កើតចេញជាកម្មវិធីសមស្របមួយ។

ក្នុងការបង្កើតកម្មវិធីមួយ អ្នកបង្កើតកម្មវិធីត្រូវសិក្សាដោយលើកជាសំណើរអំពីការចំណាយ និងពេលវេលា។ បន្ទាប់ពីគម្រោងសិក្សាត្រូវបានទទួលការឯកភាព អ្នកបង្កើតកម្មវិធីត្រូវសហការជាមួយអ្នកជំនាញពាក់ព័ន្ធដើម្បីបង្កើតឱ្យចេញជារូបរាងកម្មវិធីដែលអាចប្រើប្រាស់បាន។ អ្នកបង្កើតកម្មវិធីត្រូវសរសេរពីលក្ខណៈពិសេសរបស់កម្មវិធី និងវិធីប្រើប្រាស់ដែលបង្កនូវលក្ខណៈងាយស្រួលដល់អ្នកប្រើទូទៅ។

## ការអប់រំ និងការបណ្ដុះបណ្ដាល

ដើម្បីអាចក្លាយខ្លួនជាអ្នកបង្កើតកម្មវិធីកុំព្យូទ័រ គេត្រូវសិក្សាកម្រិតបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ព្រមទាំង តម្រូវការបទពិសោធន៍ការងារក្នុងការប្រើប្រាស់ភាសាក្នុងកម្មវិធីកុំព្យូទ័រ។ បន្ថែមលើនេះ អ្នកត្រូវបច្ចេកទេសត្រូវមានចំណេះដឹងក្នុងផ្នែកដែលខ្លួនចង់រចនា ឬបង្កើតកម្មវិធីនោះ ដូចជា វិស័យអប់រំ ជំនួញ និងវិទ្យាសាស្ត្រ ជាដើម។ ឧទាហរណ៍ អ្នកដែលមានឯកទេសខាងវិទ្យាសាស្ត្រកុំព្យូទ័ររួមជាមួយនិងជំនាញបន្ទាប់បន្សំផ្នែកជំនួញ ឬគណនេយ្យនឹងបង្កលក្ខណៈងាយស្រួលដល់ការបង្កើតកម្មវិធី ដែលពាក់ព័ន្ធនឹងការបង្កើតកម្មវិធីកុំព្យូទ័រផ្នែកជំនួញ និងគណនេយ្យ។

### គួរយល់ដឹង !

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

វិទ្យាសាស្ត្រកុំព្យូទ័រ និងគណិតវិទ្យា

✦ **កម្រិតអប់រំទាបបំផុត:**

បរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្ដីពីអ្នកមានជំនាញស្រដៀងគ្នា:**

អ្នកឯកទេសផ្នែកមូលដ្ឋានទិន្នន័យ និង
វិស្វករផ្នែកកម្មវិធីកុំព្យូទ័រ ជាដើម។

# អ្នកផ្សាយកម្មវិធីវិទ្យុ និងទូរទស្សន៍

(Radio and Television Announcers)

សង្ខេបអំពីជំនាញ

អ្នកផ្សាយកម្មវិធីវិទ្យុ និងទូរទស្សន៍ធ្វើការងារ៖

- ប្រាស្រ័យទាក់ទងផ្នែកគំនិត
- វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
- បំពេញការងារជាក្រុម

ជំនាញដែលត្រូវការប្រើ៖

- ការគិតប្រកបដោយភាពច្នៃប្រឌិត
- ការអាន និងការសរសេរ
- ការនិយាយ និងការស្តាប់

## តើអ្នកផ្សាយកម្មវិធីវិទ្យុ និងទូរទស្សន៍បំពេញកិច្ចការអ្វីខ្លះ?

អ្នកផ្សាយកម្មវិធីវិទ្យុ និងទូរទស្សន៍គឺជាអ្នកអានឈ្មោះ និងលេខរបស់ស្ថានីយ៍ ប្រកាសអំពីពេលម៉ោងសម្រាក ការផ្សាយបើក និងបិទកម្មវិធី ការប្រកាសផ្សាយអំពីសេវាសាធារណៈ។ អ្នកផ្សាយវិទ្យុធ្វើការសម្ភាសន៍ភ្ញៀវដែលចូលរួមកម្មវិធី ឬសម្របសម្រួលកម្មវិធីពិភាក្សា។

អ្នកផ្សព្វផ្សាយមានតួនាទីច្រើន ដូចជា អ្នកចាក់ភ្លេង ឬតន្ត្រី (disc jockeys) សម្រាប់កំដរក្នុងកម្មវិធីផ្សាយពាណិជ្ជកម្ម និងការជជែកផ្សេងៗ។ ជួនកាលពួកគេអានព័ត៌មាន ការព្យាករណ៍អាកាសធាតុ និងព័ត៌អំពីចរាចរណ៍។ ជាទូទៅ ការនិយាយរបស់ពួកគេពុំមានសរសេរព្រាងទុកទេ លើកលែងតែព័ត៌មានខ្លះៗដូចជា ការផ្សាយពាណិជ្ជកម្ម និងសេចក្តីរាយការណ៍ព័ត៌មានតែប៉ុណ្ណោះ។

ចំណែកឯពិធីករផ្នែកកម្មវិធីកីឡានឹងធ្វើពិពណ៌នាអំពីព្រឹត្តិការណ៍កីឡា។ អ្នកផ្សព្វផ្សាយផ្នែកនេះត្រូវមានចំណេះដឹងអំពីកីឡាជាច្រើនប្រភេទ ដើម្បីអាចឱ្យគេធ្វើការផ្សព្វផ្សាយបានត្រឹមត្រូវ ឆាប់រហ័សទាន់ពេលវេលាទៅតាមព្រឹត្តិការណ៍នីមួយៗ។ គួរកត់សម្គាល់ថា កីឡាប្រភេទខ្លះដែលមានសកម្មភាពរហ័សរហួននៅពេលប្រកួត ដូចជាបាល់ទាត់ ជាដើម តម្រូវឱ្យអ្នកពិពណ៌នាមានភាពស្ទាត់ជំនាញក្នុងការបរិយាយអំពីសកម្មភាពរបស់កីឡាករ ដោយមិនបង្អង់ និងមិនមានការភ័ន្តច្រឡំ។

អ្នកផ្សព្វផ្សាយព័ត៌មានមានជំនាញក្នុងការរាយការណ៍ព័ត៌មាន ដែលរួមទាំងព្រឹត្តិការណ៍ក្នុងប្រទេស ក្នុងតំបន់ និងអន្តរជាតិ។ អ្នកផ្សព្វផ្សាយព័ត៌មានខ្លះអាចបរិយាយបន្ថែមបន្ថយទៅលើព័ត៌មានដោយបញ្ចូលគំនិត និងអំណះអំណាងផ្សេងៗ។ អ្នកផ្សព្វផ្សាយព័ត៌មានអាចសរសេរអត្ថបទព័ត៌មានដោយខ្លួនឯង ឬអានតែទៅតាមអ្វីដែលបានសរសេរបញ្ជូនមកដោយអ្នកយកព័ត៌មាន។ គួរកត់សម្គាល់ថា អ្នកផ្សាយព័ត៌មានអាចផ្សាយជាច្រើនលើកទៅតាមកម្មវិធី ឬផ្សាយព័ត៌មានខ្លីៗទាន់ហេតុការណ៍ក្នុងចន្លោះកម្មវិធីផ្សាយដទៃ។ គេសង្កេតឃើញថា អ្នកផ្សាយព័ត៌មានក៏ត្រូវបានបែងចែកជាជំនាញ ឬការទទួលខុសត្រូវតាមផ្នែកផ្សេងៗគ្នា ដូចជាព័ត៌មានសេដ្ឋកិច្ច នយោបាយ សុខភាព និងសន្តិសុខ ។ល។



## ការអប់រំ និងការបណ្តុះបណ្តាល

អ្នកធ្វើការផ្នែកផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ គួរមានកម្រិតអប់រំទាបបំផុតត្រឹមបរិញ្ញាបត្រលើមុខវិជ្ជាសំខាន់ៗមួយចំនួនដូចជា ផ្នែកអក្សរសាស្ត្រ សារព័ត៌មានវិទ្យា និងភាសាបរទេស ជាដើម។ ក្រៅពីនេះពួកគេគួរសិក្សាបន្ថែមលើជំនាញក្នុងការធ្វើអត្ថាធិប្បាយ និងវិភាគអំពីព័ត៌មាន។ នៅប្រទេសកម្ពុជា គេសង្កេតឃើញថាការងារផ្នែកផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ច្រើនតែហាត់រៀន ឬទទួលបានចំណេះតាមរយៈការបំពេញការងារផ្ទាល់នៅតាមស្ថានីយ៍វិទ្យុ ឬទូរទស្សន៍ ដោយពុំទាន់មានសាលាបច្ចេកទេស ឬសាលាបណ្តុះបណ្តាលណាមួយផ្តល់នូវការអប់រំជាពិសេសបែបនេះនៅឡើយទេ។

## គួរយល់ដឹង !

✦ មុខវិជ្ជាសិក្សាក្នុងសាលា:

ការធ្វើបទអត្ថាធិប្បាយ និងភាសាបរទេស

✦ កម្រិតអប់រំទាបបំផុត:

បរិញ្ញាបត្រ ឬបរិញ្ញាបត្ររង

✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:

វិស្វករផ្នែកការផ្សព្វផ្សាយ

អ្នកចាក់បទភ្លេង

អ្នកផលិតកម្មវិធីវិទ្យុ និង

អ្នកនិពន្ធ ។ល។




# វេជ្ជបណ្ឌិតផ្នែកការវះកាត់

( Surgeons )

**សង្ខេបអំពីជំនាញ**

**វេជ្ជបណ្ឌិតផ្នែកការវះកាត់ធ្វើការងារ៖**

✦ ដឹកនាំការងារក្នុងភាពជាអ្នកដឹកនាំ

✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន

✦ បំពេញការងារជាក្រុម

**ជំនាញដែលត្រូវការច្រើន៖**

✦ ការគិតប្រកបដោយភាពច្នៃប្រឌិត

✦ ការអនុវត្តកិច្ចការប្រកបដោយហេតុផល

✦ ការនិយាយ និងការស្តាប់

## តើវេជ្ជបណ្ឌិតផ្នែកការវះកាត់បំពេញកិច្ចការអ្វីខ្លះ?

វេជ្ជបណ្ឌិតផ្នែកការវះកាត់មានឯកទេសក្នុងការវះកាត់ទៅលើអ្នកជម្ងឺ ដើម្បីធ្វើការព្យាបាលកន្លែងដែលមានរបួស ឬបាក់ស្រាំ វះកាត់យកផ្នែកខ្លះដែលជាជម្ងឺចេញពីរាងកាយរបស់មនុស្ស។ បន្ថែមលើនេះ វេជ្ជបណ្ឌិតផ្នែកវះកាត់ក៏បំពេញការងារផ្នែកវះកាត់កែសម្រួលផ្នែកខ្លះនៃរាងកាយដែលមិនមានដំណើរការទៅតាមប្រក្រតីភាព។

វេជ្ជបណ្ឌិតខ្លះបំពេញការងារក្នុងការវះកាត់ទូទៅ រីឯវេជ្ជបណ្ឌិតផ្សេងទៀតមានឯកទេសពិសេសចំពោះតែការវះ - កាត់ផ្នែកណាមួយនៃរាងកាយ ឬសរីរាង្គរបស់មនុស្សតែប៉ុណ្ណោះ។ ក្នុងចំណោមនោះ គេសង្កេតឃើញមានវេជ្ជ-

តទៅទំព័របន្ទាប់

គេសង្កេតឃើញមានវេជ្ជបណ្ឌិតឯកទេសខាងការតឆ្អឹងបាក់ស្រាំ (ឆ្អឹងដៃ ឬជើង) ព្រមទាំងធ្វើការវះកាត់ និងព្យាបាលជម្ងឺដែលពាក់ព័ន្ធឆ្អឹង ឬនៅក្នុងខួរឆ្អឹងផងដែរ។

វេជ្ជបណ្ឌិតផ្នែកជម្ងឺខួរក្បាល និងសរសៃឈាមក្នុងខួរក្បាលមានឯកទេសផ្នែកថតឆ្លុះ និងកំណត់មុខសញ្ញាជម្ងឺមុននឹងធ្វើការវះកាត់ ឬព្យាបាល។ ចំណែកវេជ្ជបណ្ឌិតខ្លះទៀតមានឯកទេសខាងការវះកាត់ និងព្យាបាលរបួស ឬជម្ងឺនៅក្នុងទ្រូងដូចជា សួត បេះដូង និងបំពង់អាហារ ជាដើម។ ដោយឡែកវេជ្ជបណ្ឌិតផ្នែកវះកាត់កែសម្ផស្សវិញមានតួនាទី និងឯកទេសខាងវះកាត់បន្ថែមទៅលើផ្នែកណាមួយនៃរាងកាយខាងក្រៅរបស់មនុស្ស ដូចជាការកែវះកាត់កែតម្រូវទៅលើភាពខុសប្រក្រតីនៃសរីរាង្គពីកំណើត របួស និងស្លាកស្នាមរលាកភ្លើង ជាដើម។



វេជ្ជបណ្ឌិតនឹងធ្វើការពិនិត្យជាបឋមទៅលើអ្នកជម្ងឺ ឬជនរងគ្រោះ បន្ទាប់មកសិក្សាអំពីប្រវត្តិនៃការព្យាបាល ឬការប្រើប្រាស់ឱសថពីមុនមក ព្រមទាំងលទ្ធផលនៃការធ្វើតេស្តសាកល្បងចំពោះរាងកាយ។ បន្ទាប់ពីពិនិត្យល្អិតល្អន់ទៅលើចំណុចសំខាន់ៗទាំងអស់នោះរួចហើយ វេជ្ជបណ្ឌិតនឹងវាយតម្លៃសម្រេចជាមួយអ្នកឯកទេសផ្សេងទៀតអំពីសភាពជម្ងឺ ឬអាការៈ តើវិធីវះកាត់ដែលល្អ និងសមស្របទៅនឹងសភាពរបស់អ្នកជម្ងឺបំផុត។ មុននឹងធ្វើការវះកាត់ វេជ្ជបណ្ឌិតនឹងពិគ្រោះជាមួយអ្នកជម្ងឺ ដើម្បីសុំការសម្រេចចិត្តចុងក្រោយ។



នៅក្នុងអំឡុងពេលវះកាត់ វេជ្ជបណ្ឌិតផ្នែកនេះគឺជាប្រធានដឹកនាំក្រុមវះកាត់។ ក្រុមវះកាត់រួមបញ្ចូលនូវអ្នកឯកទេសជាច្រើនដូចជា ផ្នែកថ្នាំស្ពឹក ផ្នែកជំនួយការ និងគិលានុបដ្ឋាក។ បន្ទាប់ពីការវះកាត់រួចរាល់ជាស្ថាពរ វេជ្ជបណ្ឌិតនៅតែបន្តតាមដានសភាពរបស់អ្នកជម្ងឺ ដើម្បីបញ្ជាក់ថាពួកគេជាសះស្បើយ និងវិលត្រលប់មករកប្រក្រតីភាពឡើងវិញ។

វេជ្ជបណ្ឌិតផ្នែកវះកាត់អាចធ្វើការនៅក្នុងមន្ទីរពេទ្យ និងគ្លីនិកក៏បាន។ វេជ្ជបណ្ឌិតផ្នែកនេះអាចធ្វើការវះកាត់នៅពេលយប់ ពេលថ្ងៃឈប់សម្រាក និងថ្ងៃចុងសប្តាហ៍ផងដែរ។ ចំពោះការវះកាត់ដែលមានសភាពធ្ងន់ធ្ងរ និងលំបាកអាចត្រូវចំណាយពេលជាច្រើនម៉ោងដើម្បីសម្រេចឱ្យចប់ជាស្ថាពរ។ នៅក្នុងលក្ខខ័ណ្ឌបែបនោះ វេជ្ជបណ្ឌិតត្រូវឈរច្រើនម៉ោង ផ្តោតអារម្មណ៍ឱ្យបានល្អ អនុវត្តនូវជំនាញដ៏ប៉ិនប្រសប់ និងឈរនៅមួយកន្លែង។




តទៅទំព័របន្ទាប់

## ការអប់រំ និងការបណ្តុះបណ្តាល

ដើម្បីអាចក្លាយខ្លួនជាវេជ្ជបណ្ឌិតផ្នែកវះកាត់ដ៏ល្អ មានជំនាញ និងឯកទេសជាក់លាក់គឺតម្រូវឱ្យសិក្សារៀនសូត្រក្នុងរយៈពេលដ៏យូរឆ្នាំ។ ពួកគេត្រូវចាប់ផ្តើមពីការសិក្សា និងបណ្តុះបណ្តាលលើមុខវិជ្ជាសំខាន់ៗ ដូចជា ជីវវិទ្យា គីមីវិទ្យា សុខភាព គណិតវិទ្យា និងភាសាបរទេស តាំងពីនៅវិទ្យាល័យ។ ជាពិសេស ពួកគេគួរសិក្សាឱ្យបានច្បាស់បន្ថែមទៀតចំពោះមុខវិជ្ជាជីវវិទ្យា និងគីមីវិទ្យា។ បន្ទាប់មកបន្តគួរការសិក្សានៅមហាវិទ្យាល័យដោយជ្រើសរើសយកឯកទេសខាងវះកាត់ និងមន្ទីរពិសោធន៍។ បន្ទាប់ពីបញ្ចប់ការសិក្សា អ្នកអាចហាត់បម្រើការងារនៅក្នុងមន្ទីរពេទ្យណាមួយដើម្បីដកស្រង់នូវបទពិសោធន៍ និងពង្រីកជំនាញមុនពេលអាចអនុវត្តកិច្ចការវះកាត់ក្នុងពេលអនាគត។



## គួរយល់ដឹង !

✦ មុខវិជ្ជាសិក្សាក្នុងសាលា:

ជីវវិទ្យា គីមីវិទ្យា និងសុខភាព

✦ កម្រិតអប់រំទាបបំផុត:

សញ្ញាបត្រវេជ្ជបណ្ឌិត

✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:

គិលានុបដ្ឋាក

វេជ្ជបណ្ឌិតផ្នែកវះកាត់កែសម្ផស្ស និង

វេជ្ជបណ្ឌិតផ្នែកជម្ងឺបេះដូង ជាដើម។

# ឱសថការី

( Pharmacists )

**សង្ខេបអំពីជំនាញ**

**ឱសថការីធ្វើការងារៈ**

✦ ទំនាក់ទំនងផ្នែកគំនិត

✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន

✦ បង្រៀន

**ជំនាញដែលត្រូវការប្រើៈ**

✦ គណិតវិទ្យា

✦ ការអាន/ការសរសេរ

✦ ការនិយាយ/ការស្តាប់

## តើឱសថការីធ្វើកិច្ចការអ្វីខ្លះ?

ឱសថការីពិនិត្យ ផ្តល់ និងលក់ឱសថដែលវេជ្ជ-បណ្ឌិត ទន្តពេទ្យ និងអ្នកឯកទេសវិជ្ជាជីវៈផ្នែកព្យាបាលជម្ងឺដទៃទៀតចេញវេជ្ជបញ្ជាទៅដល់អ្នកជម្ងឺ ឬអតិថិជនរបស់ពួកគេ។

គេសង្កេតឃើញថា មានឱសថរាប់ពាន់ប្រភេទត្រូវបានផលិត និងកំពុងចរាចរនៅក្នុងទីផ្សារ ដូច្នេះឱសថការីត្រូវមានចំណេះដឹងច្បាស់លាស់អំពីសារជាតិគីមីនានា ដែលមាននៅក្នុងឱសថមួយប្រភេទៗ ដើម្បីតម្រូវទៅតាមអាការៈជម្ងឺ និងសរីរាង្គរបស់អ្នកជម្ងឺ ក៏ដូចជាភាពស័ក្តិសិទ្ធិ និងផលប៉ះពាល់នៃឱសថទាំងនោះនៅគ្រប់ពេលនៃការព្យាបាល។

តទៅទំព័របន្ទាប់

ឱសថការីត្រូវតែមានចំណេះ និងលទ្ធភាពក្នុងការពន្យល់អំពីឱសថនីមួយៗទៅដល់អ្នកជម្ងឺ ឬអតិថិជន អំពីការប្រើប្រាស់ និងផលប៉ះពាល់ផ្សេងទៀតក្រៅតែពីលទ្ធភាពនៅក្នុងការព្យាបាលជម្ងឺរបស់ឱសថទាំងនោះ។ បន្ថែមពីលើនេះ ឱសថការីក៏ត្រូវមានចំណេះដឹងក្នុងការលក់ និងផ្តល់នូវឱសថជាច្រើនប្រភេទទៀត ដែលមិនត្រូវការចេញវេជ្ជបញ្ជា ដូចជា ឱសថព្យាបាលជម្ងឺក្អក ផ្តាសាយ ប្រភេទថ្នាំវីតាមីន និងឧបករណ៍ខ្លះៗដូចជា ប្រដាប់វាស់ស្ទង់កម្តៅ ជាដើម។

ឱសថការីដែលគ្រប់គ្រងឱសថស្ថានដោយខ្លួនឯងមានតួនាទី និងបំពេញការងារបន្ទាប់បន្សំជាច្រើនប្រៀបដូចជាអ្នកគ្រប់គ្រង និងចែកចាយឱសថដូច្នោះដែរ។ ពួកគេបញ្ជាទិញឱសថសម្រាប់លក់រាយ និងជុំ គ្រប់គ្រងបុគ្គលិកក្នុងឱសថ-ស្ថាន និងគ្រប់គ្រងចាត់ចែងចំពោះហរិញ្ញវត្ថុទៀតផង។

នៅតាមមន្ទីរពេទ្យ គ្លីនិក និងស្ថាប័នព្យាបាលជម្ងឺផ្សេងៗតែងមានឱសថការីបម្រើការជាបុគ្គលិក។ ឱសថការីទាំងនោះមានភារៈផ្តល់ថ្នាំ ពន្យល់អប់រំអ្នកជម្ងឺ និងពិនិត្យទៅលើឯកសារ ឬរបាយការណ៍ឱសថនៅក្នុងស្ថាប័នទាំងមូល។ ឱសថការីខ្លះបង្រៀនជំនាញផ្នែកនេះទៅដល់និស្សិតនៅតាមមហាវិទ្យាល័យផ្នែកសុខាភិបាល និងផ្នែកគិលានុបដ្ឋាក។ អ្នកខ្លះទៀតធ្វើការនៅក្នុងក្រុមហ៊ុនផលិតឱសថ ដែលការងារផ្នែកនេះ ទំនងជាមានពាក់ព័ន្ធជាមួយនឹងការស្រាវជ្រាវអំពីឱសថថ្មីៗ ដើម្បីផ្សំបង្កើតជាប្រភេទថ្នាំគ្រាប់ ថ្នាំទឹក ជាដើម។ ឱសថការីខ្លះមានភារៈធ្វើតេស្តសាកល្បងចំពោះជាតុផ្សំ ឬសារជាតុគីមីនៅក្នុងឱសថមុនពេលធ្វើការផលិតសម្រេច។

ដើម្បីអាចក្លាយខ្លួនជា ឱសថការីដ៏ល្អមួយរូប អ្នកត្រូវការនូវជំនាញទំនាក់ទំនងដែលអាចជួយសម្រួលក្នុងការជួបពិគ្រោះជាមួយអ្នកជម្ងឺ ឱសថការី និងអ្នកឯកទេសវិជ្ជាជីវៈផ្នែកព្យាបាលជម្ងឺផ្សេងទៀត។ បន្ថែមលើនេះ ឥរិយាបថរួសរាយរាក់ទាក់ ក៏ជាកត្តាជួយឱ្យបំពេញការងារបានប្រសើរនៅក្នុងមន្ទីរពេទ្យ គ្លីនិក និងមន្ទីរព្យាបាលផ្សេងៗ ជាពិសេសត្រូវកត់ចំណាំថា តួនាទីរបស់ឱសថការី គឺផ្តល់នូវដំបូន្មាន និងយោបល់ទៅដល់អ្នកជម្ងឺ។

## ការអប់រំ និងការបណ្តុះបណ្តាល

ដើម្បីអាចក្លាយខ្លួនទៅជាឱសថការីស្របទៅតាមបច្ចេកទេសវេជ្ជសាស្ត្រ អ្នកត្រូវសិក្សាជំនាញនេះនៅមហាវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល។ ជំនាញផ្នែកឱសថសាស្ត្រ គឺតម្រូវឱ្យនិស្សិតសិក្សាលើមុខវិជ្ជាសំខាន់ៗមួយចំនួនដូចជា វិទ្យាសាស្ត្រផ្នែកឱសថ គីមីនៃការរូបមានជីវិត ច្បាប់ និងក្រមសីលធម៌ផ្នែកឱសថសាស្ត្រ ព្រមទាំងការថែទាំឱសថសាស្ត្រ។ បន្ថែមលើនេះ ការអប់រំក៏ត្រូវរួមបញ្ចូលនូវការធ្វើកម្មសិក្សាការងារ ដែលបម្រើការនៅក្រោមការគ្រប់គ្រង និងផ្តល់យោបល់របស់អ្នកឯកទេសវិជ្ជាជីវៈ។

គួរបញ្ជាក់ផងដែរថា ការបម្រើការងារជាឱសថការីតម្រូវឱ្យមានអាជ្ញាប័ណ្ណដែលចេញដោយក្រសួងពាក់ព័ន្ធមុននឹងអាចប្រកបរបរវិជ្ជាជីវៈ ឬអាជីវកម្ម។

### គួរយល់ដឹង !

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

គីមីវិទ្យា និងគណិតវិទ្យា

✦ **កម្រិតអប់រំទាបបំផុត:**

បណ្ឌិតផ្នែកឱសថសាស្ត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

អ្នកគីមីផ្នែកការរូបមានជីវិត

អ្នកគីមីវិទ្យា

អ្នករូបវិទ្យា និង អ្នកផលិតឱសថ ជាដើម។


តទៅទំព័របន្ទាប់

ការរៀបចំមូលដ្ឋានគ្រឹះ




ក្នុងការស្វែងរកការងារធ្វើ

# ការចរចាប្រាក់បៀវត្ស និង ការសម្រេចចិត្តទទួលយកការងារ



នៅពេលទទួលបានការងារជាលើកដំបូងក្នុងជីវិត អ្នកស្វែងរកការងារធ្វើភាគច្រើនតែងសម្តែងនូវក្តីអររំភើបជាពន់ពេក ដែលជាហេតុបណ្តាលឱ្យពេលខ្លះ ពួកគេភ្លេចទាំងសួរនាំនូវសំណួរសំខាន់ៗទៅកាន់និយោជក ដូចជាសំណួរអំពីប្រាក់បៀវត្ស ការទទួលខុសត្រូវក្នុងការងារ និងស្ថានភាពផ្សេងៗទៀតរបស់ការងារ។ អ្នកស្វែងរកការងារខ្លះទំនងជាមានការបារម្ភក្នុងការជជែកចរចាអំពីបញ្ហាប្រាក់ខែ ឬបរិយាកាសនៅក្នុងកន្លែងការងារ។ អ្នកខ្លះទៀត មានភាពសប្បាយក្នុងចិត្ត ហើយយល់ព្រមទទួលនូវការផ្តល់ជូនពីនិយោជក ទោះបីជានៅក្នុងលក្ខខ័ណ្ឌណាក៏ដោយ។

វាមិនមែនជាការល្អនោះទេ ដែលអ្នកមិនបានសាកសួរឱ្យបានលម្អិតអំពីស្ថានភាពការងារអ្វីមួយ មុនពេលដែលអ្នកយល់ព្រមទទួលបំពេញការងារនោះ ដោយគិតចាប់ពីការទទួលខុសត្រូវក្នុងការងារ ប្រាក់បៀវត្ស និងលាភសក្ការៈផ្សេងៗទៀត។ ប្រសិន អ្នកខកខានមិនបានសាកសួរឱ្យបានច្បាស់លាស់នូវបញ្ហានេះទេ គឺចាត់ទុកថាអ្នកមានការខាតបង់នូវផលប្រយោជន៍ និងពេលវេលា ខណៈពេលដែលអ្នកកំពុងធ្វើនូវកិច្ចការមួយដែលខ្លួនមិនសូវពេញចិត្ត ហើយដែលមិនត្រូវទៅតាមជំនាញ និងចំណូលចិត្តរបស់ខ្លួន។

## ការស្គាល់អំពីខ្លួនឯង

យើងសង្ឃឹមថារហូតមកដល់ដំណាក់កាលនេះ អ្នកបានស្វែងយល់អំពីខ្លួនឯងយ៉ាងល្អិតល្អន់។ អ្នកបានបញ្ចប់ការសិក្សា ចូលរួមក្នុងកម្មសិក្សា បំពេញសកម្មភាពស្ម័គ្រចិត្ត បំពេញការងារក្រៅម៉ោង ស្គាល់អំពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ខ្លួន វិភាគអំពីការងារ និងជំនាញសម្រាប់សរសេរក្នុងប្រវត្តិរូប។ អ្នកដឹងប្រភេទនៃជំនាញរបស់អ្នក ព្រមទាំងចំណូលចិត្តផ្សេងៗ ដូចជា ការនិយាយ ការសរសេរ ការដោះស្រាយបញ្ហា ការជួយយកអាសារអ្នកដទៃ និងការស្រាវជ្រាវ ជាដើម។



*អត្ថបទដកស្រង់ និងប្រែសម្រួលដោយ **ហៃ ហ៊ុនឡេង**។ សម្រាប់ព័ត៌មានបន្ថែមសូមអញ្ជើញរកអានឯកសារស្តីពីអាជីព និងការងារដែលមានតម្កល់ទុកនៅក្នុង **«បណ្ណាល័យការងារ»** របស់ទីភ្នាក់ងារជាតិមុខរបរ និងការងារដោយមេត្រី។*

តទៅទំព័របន្ទាប់

ការយល់ដឹងទាំងអស់នេះគួរតែទទួលជ្រួតជ្រាបចាប់តាំងពីអំឡុងពេលស្វែងរកការងារមកម្ល៉េះ ជាពិសេសនៅពេលដែលនិយោជកផ្តល់ការងារឱ្យរូបអ្នក។ តាមរយៈការស្គាល់ពីខ្លួនឯងបែបនេះ អ្នកប្រាកដជាដឹងថាការងារដែលសម ឬមិនសមជាមួយខ្លួនឯង ហើយគួរទទួលយក ឬក៏អត់? ប្រហែលជាអ្នកចង់សាកល្បងទទួលយកនូវការងារមួយដែលមិនស័ក្តិសមជាមួយចំណូលចិត្ត និងជំនាញ ប៉ុន្តែមានកម្រិតប្រាក់បៀវត្សខ្ពស់។ អ្នកជំនាញផ្នែកអាជីព និងការងារផ្តល់យោបល់ថាអ្នកមិនគួរជ្រើសយកការងារបែបនោះទេ ដោយហេតុថា ការទទួលបានប្រាក់កម្រៃច្រើននឹងមិនបានជួយរូបអ្នកឱ្យបំពេញការងារដោយពេញចិត្ត ហើយបង្កើតបានជោគជ័យដ៏ត្រចះត្រចង់នោះឡើយ។

ខាងក្រោមនេះគឺជាសំណួរខ្លះៗដែលជួយតម្រង់ផ្លូវឱ្យអ្នកស្វែងរកការងារធ្វើកំណត់អំពីភាពស៊ីសង្វាក់ និងភាពស័ក្តិសមរវាងរូបគេទៅនឹងការងារ៖

- ✪ តើអ្វីខ្លះជាការទទួលខុសត្រូវរបស់ខ្ញុំក្នុងការងារ?
- ✪ តើខ្ញុំមានជំនាញជាក់លាក់ណាមួយសម្រាប់បំពេញការងារដែរឬទេ?
- ✪ តើម៉ោងបំពេញការងារមានសភាពដូចម្តេចដែរ?
- ✪ តើការងារនេះតម្រូវឱ្យខ្ញុំធ្វើដំណើរទៅទីឆ្ងាយៗដែរឬទេ? ប្រសិនបើមាន តើត្រូវធ្វើដំណើរញឹកញាប់ដែរឬទេ?
- ✪ តើខ្ញុំត្រូវធ្វើការនៅក្នុងការិយាល័យ ឬនៅខាងក្រៅ ឬក៏ទាំងពីរកន្លែង?
- ✪ តើខ្ញុំនឹងតម្រូវឱ្យធ្វើការលើសម៉ោងដែរឬទេ? ប្រសិនមាន តើត្រូវធ្វើញឹកញាប់ដែរឬទេ? តើមានបន្ថែមប្រាក់ដែរឬទេ?
- ✪ តើមានលាភសក្ការៈ ឬផលប្រយោជន៍ផ្សេងក្រៅពីប្រាក់ខែដែរឬទេ?

## តើអ្នកមានតម្លៃខ្លួនប៉ុន្មាន?

តើអ្នកដឹងថាមនុស្សដែលមានការអប់រំ និងជំនាញដូច ឬស្រដៀងរូបអ្នកទទួលបានប្រាក់បៀវត្សប៉ុន្មាន? ប្រសិនអ្នកមិនបានដឹងរឿងនេះ អ្នកនឹងស្ថិតក្នុងភាពខាតបង់នៅក្នុងពេលនិយោជកផ្តល់ការងារឱ្យរូបអ្នក។ ប្រការដែលល្អគឺអ្នកគួរសិក្សាស្រាវជ្រាវអំពីកម្រិតប្រាក់បៀវត្សរបស់បុគ្គលិកដែលមានជំនាញដូចអ្នកនៅពេលចាប់ផ្តើមការងារដំបូង។

តើអ្នកអាចរកព័ត៌មានប្រភេទនេះកន្លែងណា? អ្នកអាចសាកសួរមិត្តភ័ក្តិដែលមានជំនាញដូចគ្នា ហើយដែលកំពុងបំពេញការងារស្រដៀងគ្នា។ ដោយសារនៅប្រទេសកម្ពុជាពុំទាន់មានការសិក្សាចងក្រងអំពីកម្រិតប្រាក់បៀវត្សនៃប្រភេទការងារនីមួយៗ ដូច្នេះ គេមិនអាចរកព័ត៌មាននេះបានទេ ក្រៅតែពីការសួរនាំទៅអ្នកដែលធ្លាប់មានបទពិសោធន៍បំពេញការងារ។ ទោះជាយ៉ាងណាក៏ដោយ ការសាកសួរទោះបានព័ត៌មានខ្លះៗក្តី ក៏គង់មានប្រយោជន៍ជាងការដែលមិនបានស្វែងយល់ទាល់តែសោះ។

## តើគួរចរចាបែបណាដើម្បីទទួលបានប្រាក់បៀវត្សខ្ពស់?

សូមអ្នកស្វែងរកការងារធ្វើ និងអ្នកដែលទទួលបានការងារកុំមានការរារែកចំពោះការចរចាជាមួយនិយោជកលើករណីប្រាក់បៀវត្ស។ មានន័យថា ការចរចាចង់បានប្រាក់ខែខ្ពស់គឺជាសិទ្ធិរបស់អ្នក ដរាបណាអ្នកធ្វើឡើងដោយមានរបៀប និងអំណះអំណាងត្រឹមត្រូវ ដែលគោរពទៅតាមលក្ខខណ្ឌនានានៃទីផ្សារការងារ។ ហេតុនេះ តើអ្នកគួរចរចា

*បែបណាជាមួយនិយោជក នៅពេលដែលអ្នកទទួលបានប្រាក់បៀវត្សទាបជាងអ្វីដែលអ្នករំពឹងគិត?*

*សូមពិនិត្យមើលលើចំណុចគន្លឹះខ្លះៗ ដែលគួរចងចាំនៅពេលចរចាអំពីប្រាក់បៀវត្ស៖*

## គន្លឹះក្នុងការចរចាអំពីប្រាក់បៀវត្ស

❶ សញ្ជឹងគិតបន្តិច! ដោយមិនត្រូវឆ្លើយភ្លាមៗទៅនឹងសំណួរអំពីប្រាក់បៀវត្សនោះទេ។ តាមរយៈកាយវិការបែបនេះ វាគឺជាសញ្ញាដែលបង្ហាញទៅដល់ភ្នាក់ងារជ្រើសរើសបុគ្គលិក ឬនិយោជកថាអ្នកមិនសូវពេញចិត្តចំពោះប្រាក់បៀវត្សដែលត្រៀមផ្តល់ឱ្យ។ ក្នុងន័យនេះ ភ្នាក់ងារជ្រើសរើសបុគ្គលិករបស់ក្រុមហ៊ុនអាចនឹងសាកល្បងតម្លើងប្រាក់បៀវត្សឱ្យខ្ពស់ជាងមុនបន្តិច ឬក៏ទុកពេលឱ្យអ្នកគិតជាមុន ហើយផ្តល់ចម្លើយនាពេលក្រោយ។

❷ ប្រសិនបើ អ្នកបានសិក្សាស្រាវជ្រាវអំពីកម្រិតប្រាក់បៀវត្សមុនពេលចូលសម្ភាសន៍ អ្នកអាចឆ្លើយបដិសេធន៍ចំពោះការផ្តល់នូវប្រាក់បៀវត្ស ដែលមានតម្លៃទាបជាងលក្ខខ័ណ្ឌទូទៅនៅក្នុងទីផ្សារ-ការងារ។ ចំណុចគន្លឹះនៅក្នុងការស្រាវជ្រាវនេះ គឺគួរផ្តល់នូវកម្រិតប្រាក់បៀវត្សបីប្រភេទ៖ ទី១ ប្រាក់បៀវត្សដែលមានចំនួនពិតប្រាកដ។ ទី២ ប្រាក់បៀវត្សដែលអ្នកអាចពឹងអាស្រ័យក្នុងការរស់នៅ។ ទី៣ ប្រាក់បៀវត្សទាបពេកដែលអាចនាំឱ្យអ្នកបោះបង់ចោលការងារ។

❸ នៅក្នុងខណៈពេលដែលរូបអ្នកបានត្រៀមខ្លួនរួចជាស្រេចចំពោះការ បដិសេធន៍ចំពោះបញ្ហាប្រាក់បៀវត្ស អ្នកគួរនិយាយថា៖ តាមរយៈការស្រាវជ្រាវរបស់ខ្ញុំបានបង្ហាញថា កម្រិតប្រាក់បៀវត្សសម្រាប់បុគ្គលិកដែលមានការអប់រំ ជំនាញ និងបទពិសោធន៍ដូចខ្ញុំគឺទទួលបានចំនួន______$។ ខ្ញុំមានជំនឿថា កម្រិតជំនាញរបស់ខ្ញុំអាចទទួលបានប្រាក់បៀវត្សក្នុងកម្រិតនេះ។ តើលោក/លោកស្រី (និយោជក) អាតម្លើងកម្រិតប្រាក់បៀវត្សនេះដែរឬទេ?

❹ បន្ទាប់មកទៀត និយោជក ឬភ្នាក់ងារជ្រើសរើសបុគ្គលិកអាចឯកភាពទៅនឹងសំណើររបស់អ្នក ឬក៏បដិសេធន៍ចំពោះការតម្លើងកម្រិតប្រាក់បៀវត្ស ហើយទុកពេលឱ្យអ្នកធ្វើការសម្រេចចិត្ត។

# តើគួរឆ្លើយបែបណា នៅនឹងសំណួរអំពីប្រាក់បៀវត្ស ក្នុងពេលសម្ភាសន៍ការងារ?

*ការពិត បញ្ហាប្រាក់បៀវត្សមិនគួរជជែកពិភាក្សានៅក្នុងអំឡុងពេលសម្ភាសន៍ការងារនោះទេ ប្រសិនភ្នាក់ងារជ្រើសរើសបុគ្គលិក ឬនិយោជកមិនទាន់និយាយថាព្រមផ្តល់ការងារឱ្យអ្នក ឬព្រមជ្រើសរើសយករូបអ្នកឱ្យបម្រើការងារ។ ប៉ុន្តែ ពេលខ្លះនិយោជកទទូចចង់ពិភាក្សាអំពីបញ្ហាប្រាក់បៀវត្សតាំងពីពេលសម្ភាសន៍ការងារដំបូងមកម្ល េះ។ តើអ្នកគួរធ្វើដូចម្តេចនៅក្នុងស្ថានភាពបែបនេះ?*

*អ្នកអាចឆ្លើយតបទៅនិយោជក ឬភ្នាក់ងារជ្រើសរើសបុគ្គលិកវិញតាមរយៈរបៀបដូចខាងក្រោម៖*

- អ្នកអាចនិយាយថា៖ ប្រសិនបើអ្នក (និយោជក) មិនយល់ទាស់ទេ ខ្ញុំមានបំណងរង់ចាំពិភាក្សាអំពីបញ្ហាប្រាក់បៀវត្សរហូតដល់ពេលដែលការសម្ភាសន៍បានចប់សព្វគ្រប់ ហើយយើងទាំងពីរ (អ្នកស្វែងរកការងារធ្វើ និងនិយោជក) យល់ឃើញថាខ្ញុំជាបុគ្គលិកដែលសមស័ក្តិទៅនឹងការងារ។

- ប្រសិន និយោជកនៅតែទទូចចង់ឱ្យអ្នកប្រាប់ពីប្រាក់បៀវត្ស អ្នកអាចឆ្លើយតាមវិធីដូច្នេះថា៖ ខ្ញុំសប្បាយចិត្តនឹងបញ្ជាក់ពីប្រាក់បៀវត្សដែលខ្ញុំប្រាថ្នាចង់បាន ប៉ុន្តែជាបឋម តើលោក/លោកស្រី (និយោជក) អាចផ្តល់នូវព័ត៌មានលម្អិតបន្ថែមអំពីការទទួលខុសត្រូវរបស់ខ្ញុំនៅក្នុងការងារបានដែរឬទេ?

- វានឹងជាការដ៏ប្រពៃ ប្រសិនបើនិយោជកយល់ព្រមទៅនឹងសំណួររបស់អ្នកខាងលើ។ ក្នុងករណីនេះ អ្នកអាចកំណត់កម្រិតប្រាក់បៀវត្សដែលស្ថិតក្នុងចន្លោះណាមួយ ដែលមានភាពសមស្របទៅនឹងទំនួលខុសត្រូវ និងសមត្ថភាពរបស់អ្នកនៅក្នុងការងារនោះ។

- ក្នុងករណីដែលនិយោជកមិនព្រមឆ្លើយតបទៅនឹងសំណូមពររបស់អ្នក នោះអាចបញ្ជាក់បានថា និយោជកមិនទាន់បានកំណត់អំពីកម្រិតប្រាក់បៀវត្សនៅឡើយ ហើយបែរជាព្យាយាមចង់ឱ្យអ្នកដែលសម្ភាសន៍ (អ្នកស្វែងរកការងារ) នីមួយៗកំណត់នូវកម្រិតប្រាក់បៀវត្សផ្សេងៗ

តទៅទំព័របន្ទាប់

ដើម្បីជាព័ត៌មានដល់ពួកគេ (និយោជក) ហើយជាលទ្ធផលគេនឹងជ្រើសរើសយកនូវបេក្ខជនរូបណាមួយ ដែលបានបង្ហាញពីកម្រិតប្រាក់បៀវត្សទាបជាងគេ។ ប្រសិនមានករណីនេះកើតឡើងអ្នកអាចនឹងសួរខ្លួនឯងថា តើអ្នកពិតជាចង់បម្រើការងារឱ្យនិយោជកដែលគិតតែពីផលចំណេញ តាមរយៈការហ៊ានចំណាយតែប្រាក់ខែតិចតួចដោយមិនរវល់អំពីគុណភាពនៃការងារនោះដែរឬទេ?

## សូមកុំភ្លេចសាកសួរអំពីផលប្រយោជន៍ ឬលាភសក្ការៈផ្សេងៗទៀត ដែលត្រូវទទួលបាន

នៅពេលដែលអ្នកកំពុងចរចាអំពីប្រាក់បៀវត្ស សូម កុំភ្លេចសាកសួរបន្ថែមទៅកាន់និយោជក អំពីផលប្រយោជន៍ផ្សេងៗទៀតដែលអ្នកត្រូវ ឬគួរទទួលបាន ដូចជាការថែទាំសុខភាព ការឈប់សម្រាក ការឈប់នៅពេលមានជម្ងឺ និងការបែងចែកផលចំណេញ ជាដើម។ ក្រុមហ៊ុនខ្លះផ្តល់នូវផលប្រយោជន៍បន្ថែមយ៉ាងច្រើនទៅដល់បុគ្គលិក ជួនកាលចំនួននោះអាចស្មើទៅនឹងកម្រិតទាបបំផុតនៃប្រាក់ខែក៏មាន។

នៅពេលដែលអ្នកចរចាអំពីប្រាក់បៀវត្ស សូមចងចាំនូវចំណុចដ៏សំខាន់ក្នុងការពិភាក្សាដោយគោរពរាក់ទាក់ និងបង្ហាញថាអ្នកមានឆន្ទៈនៅក្នុងការសម្របសម្រួលរកដំណោះស្រាយ។ ត្រូវយល់ថា អ្នកនឹងមិនអាចទទួលបាននូវអ្វីៗគ្រប់យ៉ាងដែលអ្នកចង់បាននោះទេ ឧទាហរណ៍ អ្នកស្នើចង់បាននូវប្រាក់បៀវត្សចំនួន ១,៥០០ ដុល្លារ ប៉ុន្តែនិយោជកយល់ព្រមផ្តល់តែ ១,០០០ ដុល្លារតែប៉ុណ្ណោះ។

ម្យ៉ាងទៀត ទៅពេលចរចាអំពីប្រាក់បៀវត្សអ្នកគួរគិតអំពីទស្សនៈរបស់និយោជកចំពោះរូបអ្នកផងដែរ។ មានន័យថា និយោជកអាចយល់បានថាអ្នកជាបុគ្គលដែលមានសក្តានុពលចំពោះក្រុមហ៊ុន ប៉ុន្តែដរាបណាអ្នកមិនទាន់បានបង្ហាញពីសមត្ថភាពក្នុងការបំពេញការងារ នោះថាហេតុនាំឱ្យនិយោកនៅមានការមន្ទិលចំពោះសមត្ថភាពរបស់អ្នក តើសមនឹងទទួលនូវកម្រិតប្រាក់បៀវត្សដូចដែលបានស្នើសុំដែរឬទេ?

ហេតុផលម្យ៉ាងទៀត អាចបណ្តាលមកពីកត្តាដែលនិយោជកពុំមានថវិកាច្រើនសម្រាប់បុគ្គលិកថ្មី ហើយអ្នកក៏ជាមនុស្សម្នាក់នៅក្នុងចំណោមនោះដែរ។ ប្រសិនបើ ការផ្តល់នូវប្រាក់បៀវត្សមានកម្រិតត្រឹមតែ ១,០០០ ដុល្លារ ដូចមានក្នុងឧទាហរណ៍ ហើយការងារមានភាពស័ក្តិសមទៅនឹងរូបអ្នក ដូច្នេះ អ្នកគួរតែសាកល្បងទទួលយកការងារនោះ ហើយអរគុណទៅកាន់និយោជកដែលបានបើកឱកាសក្នុងការចរចា។

ប៉ុន្តែ ប្រសិននិយោជកមិនមានបំណងក្នុងការចរចាទេនោះ អ្នកគួរទទួលយកការងារប្រសិនវាមានភាពស៊ីសង្វាក់ទៅនឹងចំណូលចិត្ត ឬជំនាញរបស់អ្នក ហើយបន្តធ្វើការនោះឱ្យបានជោគជ័យ។ គួរចងចាំថា អ្នកមិនត្រូវនាំយកទៅជាមួយនូវភាពទោមនស្ស ឬការមិនសប្បាយចិត្តទៅក្នុងបរិយាកាសការងារ ខណៈពេលដែលការចរចាអំពីប្រាក់បៀវត្សមិនទទួលបានជោគជ័យក៏ដោយ៕





ការណែនាំអំពីវិធីបំពេញការងារ

# ការស្វែងយល់ពីតថភាព នៅក្នុងកន្លែងការងារ

ប្រិយមិត្ត និងមិត្តអ្នកអានទាំងអស់ ជាទីមេត្រី! ព្រឹត្តិបត្រការងារមានកិត្តិយសសូមនាំមកបង្ហាញជូនលោក-អ្នកនូវទំព័រថ្មីមួយទៀតសម្រាប់ការផ្សាយលេខនេះ ដែលផ្តោតជាសំខាន់ទៅលើការពន្យល់ណែនាំអំពី វិធីក្នុងការបំពេញការងារនៅក្នុងការិយាល័យ ឬក្នុងបរិបទការងារណាមួយ។

ដោយយល់ឃើញថានៅក្នុងការផ្សាយកន្លងមក យើងខ្ញុំបានបកស្រាយពន្យល់ជាហូរហែរអំពីជំនាញផ្សេងៗ វិធីក្នុងការស្វែងរកការងារធ្វើ និងវិធីសាស្រ្តក្នុងការឆ្លើយសំណួរ ជាដើម ប៉ុន្តែ ហាក់នៅមិនទាន់បានពន្យល់ឱ្យចូលជ្រៅទៅដល់គន្លឹះនៃការតម្រូវខ្លួនទៅនឹងបែបផែន ឬរបៀបនានាក្នុងការអនុវត្តការងារនៅឡើយ។ ការពិត ជីវិតការងារ និងការបំពេញការងារក្នុងអាជីពអ្វីមួយក្តី តែងតែពើបប្រទះដោយផ្ទាល់ ឬប្រយោលនូវចំណុចវិជ្ជមាន និងអវិជ្ជមានដោយខានពុំបាន។ ហេតុនេះ និយោជិតម្នាក់ៗត្រូវរិះរកមធ្យោបាយដោះស្រាយដែលប្រកបដោយប្រសិទ្ធភាពបំផុត ដើម្បីឈានទៅសម្រេចនូវការងារដែលបានដាក់ចេញដោយនិយោជក។

អាស្រ័យហេតុនេះ សូមប្រិយមិត្តទាំងអស់តាមដានស្វែងយល់អំពីវិធី និងបែបបទនានាដែលគួរប្រកាន់យក ឬគួរអនុវត្តនៅក្នុងបរិយាកាសការងាររបស់លោក-អ្នកទៅតាមការដ៏គួរ និងល្មមសមតាមការយល់ដែលគួរប្រតិបត្តិដើម្បីទទួលបាននូវជោគជ័យក្នុងជីវិតការងារ។

## បញ្ហានៅក្នុងកន្លែងការងារ និងបញ្ហារបស់អ្នក!

បច្ចុប្បន្ននេះ ការងារនៅក្នុងការិយាល័យមួយចំនួនធំគឺមានភាពប្រកួតប្រជែង ភាពរហ័សរហួន ព្រមទាំងមានក្រុមហ៊ុន និងស្ថាប័នការងារខ្លះបានផ្សារភ្ជាប់ខ្លួនយ៉ាងជិតស្និទ្ធទៅនឹងឥទ្ធិពលនៃនយោបាយ ឬបង្អែកផ្សេងៗដើម្បីរក្សានូវលំនឹងនៃការរបរជំនួញរបស់ពួកគេ។ យ៉ាងណាមិញ បុគ្គលិកនិងនិយោជិតនៅក្នុងការិយាល័យក៏គួរតែមានភាពឈ្លាសវៃ និងភាពងាយបត់បែនបន្ថែមទៅលើចំណេះ និងជំនាញដែលបានហាត់រៀន ដើម្បីទទួលអនុវត្តការងារឱ្យបានជោគជ័យមានប្រសិទ្ធិភាព ព្រមទាំងទទួលបានការលើកសរសើរ ឬកើនបុណ្យឡើងស័ក្តិមានឋានៈកិត្តិយសទៀតផង។

*អត្ថបទដកស្រង់ និងប្រែសម្រួលដោយ **ហៃ ហ៊ុនឡេង**។ សម្រាប់ព័ត៌មានបន្ថែមសូមអញ្ជើញរកអានឯកសារស្តីពីអាជីព និងការងារដែលមានតម្កល់ទុកនៅក្នុង «**បណ្ណាល័យការងារ**» របស់ទីភ្នាក់ងារជាតិមុខរបរ និងការងារដោយមេត្រី។*

តទៅទំព័របន្ទាប់

ការពោលដូច្នេះ គឺមិនមែនមានន័យថាបុគ្គលិក-និយោជិតត្រូវតែចុះញ៉ម ឬលុតក្រាបបែបអបនោះទេ ប៉ុន្តែចង់បញ្ជាក់ថា នៅក្នុងបរិដ្ឋានការងារនីមួយៗតែងមានរួមផ្សំទៅដោយសម្គាល ឬបញ្ហាស្មុគស្មាញជាច្រើនជំពូក រីឯបុគ្គលិកដទៃទៀតសោត ដែលធ្វើការនៅក្នុងការិយាល័យជាមួយគ្នាក៏មានច្រើនសណ្ឋាន រួមទាំងមនុស្សល្អ មនុស្សអាក្រក់ឈ្នានីស អ្នកព្យាបាទចង់ឈ្នះ ឬក៏ករណីខ្លះទៀតចៅហ្វាយនាយ គឺជាមនុស្សដែលពិបាកស្វែងយល់ផ្គាប់ចិត្ត។ ប៉ុន្តែ ទោះបីជាលោក-អ្នកបានជួបប្រទះនូវករណីណាមួយក៏ដោយ នៅក្នុងជីវិតការងារគឺត្រូវតែសម្របសម្រួលឱ្យបានច្រើនបំផុតដើម្បីញ៉ាំងឱ្យការងារប្រព្រឹត្តទៅដោយរលូន និងមានការផ្លាស់ប្ដូរមុខមាត់ជានិរន្តរ៍។

«ឱកាស» គឺជាប្រការដ៏គួរឱ្យព្រួយបារម្ភ ដែលមិនយូរឬមិនឆាប់លោក-អ្នកនឹងត្រូវប្រឈមជាមួយការប្រកួតប្រជែងការប៉ះទង្គិចដោយថាហេតុជាមួយនឹងបុគ្គលិកឯទៀតៗនៅក្នុងស្ថានភាពការងារដ៏តានតឹងមួយ ប្រសិនបើលោកអ្នកមិនទាន់បានទទួលនូវឱកាសនោះទេ។ នៅខណៈពេលដែលរឿងហេតុបែបនេះកើតឡើង មនុស្សភាគច្រើននឹងមានអារម្មណ៍ថាមានភាពតានតឹងក្នុងចិត្ត ហើយមានការលំបាកក្នុងការប្រឈមជាមួយហេតុការណ៍នានា បើទោះបីជារឿងនោះជារឿងតូចតាចសាមញ្ញយ៉ាងណាក្តី។ ម្យ៉ាងវិញទៀតមនុស្សម្នាក់ៗនឹងទទួលកម្រិតនៃការប៉ះពាល់ធ្ងន់ ឬស្រាលទៅតាមហេតុផល ឬស្ថានភាពតែរៀងៗខ្លួន។



## អំពីតថភាព ២បែប៖ សត្វខ្លា ឬសត្វឆ្មា?

**◙តថភាពទី១៖** តថភាពទីមួយគឺស្ថិតនៅក្នុងខ្លួនមនុស្សម្នាក់ៗ ហើយដែលមានលក្ខណៈពិសេសរៀងៗខ្លួនពីមនុស្សម្នាក់ទៅមនុស្សម្នាក់ផ្សេងទៀត។ តថភាពខាងក្នុងគឺសំដៅដល់គំនិតអារម្មណ៍ និងសកម្មភាពដែលគិត និងសម្ដែងចេញតាមបែបបញ្ជាក់ហេតុផល ឬមិនសូវមានហេតុផលនៅពេលអ្នកជួបប្រទះនូវហេតុការណ៍អាក្រក់អ្វីមួយ។ តថភាពខាងក្នុងគឺបង្ហាញឱ្យឃើញពីចំណុចខ្វះខាត ឬចំណុចងងឹតល្ងង់ (blind spots) ដែលអ្នកមិនអាចមើលយល់ និងគេចវេះចេញដោយខ្លួនឯងបាន។

ចំណុចងងឹតល្ងង់អាចបណ្ដាលមកពីបទពិសោធន៍ក្នុងអតីតកាលដែលមានភាពសោកសៅ ភាពជូរចត់ ការឈឺចាប់ចំពោះរឿងរ៉ាវអ្វីមួយនៅពេលកុមារភាព ឬក៏ទំនាក់ទំនងក្នុងគ្រួសារ ដែលមានភាពប្រេះស្រាំរកាំរកូសក្នុងរយៈពេលដ៏យូរណាមួយ។ បទពិសោធន៍ទាំងអស់នេះបានប្រែក្លាយទៅជាវិធីសាស្ត្រក្នុងការតស៊ូទ្រាំរស់ ហើយរិះរកមធ្យោបាយក្នុងការដោះស្រាយបញ្ហា និងដើម្បីសុវត្ថិភាពក៏ដូចជាការចៀសចាកអំពីក្ដីព្រួយបារម្ភទាំងពួង។ ម្យ៉ាងទៀត ចំណុចងងឹតល្ងង់ក៏អាចដៅសម្គាល់ថាជាបែបបទ ឬចរិតលក្ខណៈរបស់មនុស្សម្នាក់ៗ ដែលសម្ដែងចេញជាចំណុចអវិជ្ជមានប្រឆាំងតបទៅនឹងការពិត ឬលទ្ធភាពនានាដែលអ្នកអាចធ្វើបាន។

**◙តថភាពទី២៖** តថភាពទីពីរគឺជាសភាវៈខាងក្រៅ ដែលរួមបញ្ចូលទៅដោយកម្លាំង ឬថាមពលទាំងឡាយបង្កើតជារូប-រាង និងបែបផែន ឬបរិបទជីវិតរបស់មនុស្សគ្រប់គ្នា ដែលមនុស្សម្នាក់ៗមិនអាចគ្រប់គ្រងបានដោយផ្ទាល់ខ្លួនឯង ប៉ុន្តែវាទាមទារឱ្យមានការទទួលខុសត្រូវពីរូបយើងម្នាក់ៗជាប្រការចាំបាច់។ នៅពេលដែលសភាវៈខាងក្រៅបង្កឱ្យមានភាពច្របូកច្របល់នៅក្នុងអារម្មណ៍ ការឆ្លើយតបរបស់អ្នកអាចនឹង


តទៅទំព័របន្ទាប់

មានភាពភ័ន្តស្មារតីខុសទំនង ហើយអាចបណ្តាលឱ្យមានផលវិបាក ការបរាជ័យ និងគ្រោះថ្នាក់ផងក៏មាន។

តថភាពទាំង ២បែប របស់មនុស្សអាចធ្វើការពន្យល់ប្រៀបធៀបតាមរយៈឧទាហរណ៍ខាងក្រោម៖

ពេលនៅជាកុមារភាពប្រហែលអាយុ ៥ ឬ ៦ឆ្នាំ អ្នកបានទៅកំសាន្តនៅសួនសត្វ។ ពេលនោះអ្នកបានឃើញសត្វខ្លាដែលនៅក្នុងទ្រុង ពេលដែលសម្លឹងទៅកាន់សត្វខ្លានោះ វាបានបញ្ចេញចង្កូម គ្រហឹម និងសម្លេងស្រែកសន្ធាប់មកលើរូបអ្នកដែលជាកុមារតូច ជាហេតុធ្វើឱ្យអ្នកមានអារម្មណ៍ភ័យស្លុតតក់ក្កមាមិនហ៊ានសម្លឹងចំវាម្តងទៀត។ បន្ទាប់មក ស្ទើររាល់យប់អ្នកសុបិន្តឃើញខ្លាកំណាច ហើយភ្ញាក់ដឹងខ្លួនឡើងកណ្តាលយប់យន់ទាំងខ្លួនភ័យញ័រចំប្រប់។ អ្នកមានសុបិន្តអាក្រក់បែបនេះអស់រយៈពេលជាច្រើនខែ ទើបអារម្មណ៍បែបនេះបក់រសាត់ផាត់រសាយឆ្ងាយពីរូបអ្នក ហើយទីបំផុតអ្នកក៏លែងមានអារម្មណ៍នឹកនាពីសត្វខ្លានោះទៀត។



ពេលវេលាបានកន្លងផុតទៅយ៉ាងយូរក្រាស់ក្រៃលដែរ បច្ចុប្បន្ននេះអ្នកមានអាយុ ៣៥ឆ្នាំហើយ។ នាយប់មួយអ្នកបានដើរឆ្លងកាត់ច្រកផ្លូវតូចស្ងាត់មួយខាងក្រោយផ្ទះ ខណៈពេលកំពុងដើរតែម្នាក់ឯង ស្រាប់តែចង្កៀងហ្វាររថយន្តបានចាំងជះពន្លឺពីចម្ងាយ ដែលរំលេចចេញជាស្រមោលដ៏ធំក្រៃលែងរបស់សត្វឆ្មាមួយក្បាលដែលកំពុងតែដើរកាត់ពីមុខពន្លឺចង្កៀងរថយន្ត។ ស្រមោលដ៏ធំរបស់សត្វឆ្មាបានបង្កឱ្យអ្នកមានអារម្មណ៍ភ័យញ័រខ្លួន។ រំពេចនោះ អ្នកព្យាយាមរកមើលរំពាត់ ឬអង្កត់ឧសទុកការពារខ្លួន។ ការពិត នោះគឺគ្រាន់តែជាស្រមោលរបស់សត្វឆ្មាតូចមួយក្បាល ដែលមិនអាចបង្កគ្រោះថ្នាក់អ្វីដល់រូបអ្នកសោះឡើយ ម្យ៉ាងទៀតឆ្មានោះកំពុងដើរតែម្នាក់វាដោយមិនរវល់អើពើពីរូបអ្នកសោះផង។

ផ្ទុយទៅវិញ ប្រសិនបើស្រមោលនោះគឺជាសត្វខ្លាពិតប្រាកដមែន នោះការយល់ឃើញ និងការប្រុងប្រយ័ត្នរបស់អ្នកគឺពិតជាត្រឹមត្រូវសម្រាប់ការពារខ្លួនប្រឆាំងគ្រោះភ័យ។ ប៉ុន្តែ នៅក្នុងខណៈនោះវាគ្រាន់តែជាសត្វឆ្មាមួយក្បាលប៉ុណ្ណោះ អ្នកបែរជាមានអារម្មណ៍ភ័យខ្លាច ដែលចំណុចនេះបង្ហាញឱ្យថា អ្នកគិតសន្មត់អំពីកិច្ចការអ្វីមួយដោយមិនបានស្វែងអំពីការពិតជាក់ស្តែង។ នេះហើយដែលគេហៅថាចំណុចងងឹតល្ងង់ (blind spots) ដែលអ្នកធ្លាប់មានបទពិសោធន៍ភ័យតក់ស្លុតចំពោះសត្វខ្លានៅឯសួនសត្វ ក្នុងពេលដែលអ្នកនៅជាកុមារភាព។

ហេតុដូច្នេះហើយ អារម្មណ៍ដែលជិតដាមទៅដោយបទពិសោធន៍អាក្រក់នាពេលកន្លងមកបានកំពុងតាមលងរូបអ្នកឱ្យមមែគិតប្រដូចហេតុការណ៍ផ្សេងៗ ដែលស្រដៀងនោះថាជាការពិតដូចគ្នា ហើយជាលទ្ធផលអ្នកនឹងសម្រេចកិច្ចការអ្វីៗដោយពុំចាំបាច់ពិចារណារកការពិត និងព័ត៌មានដែលត្រឹមត្រូវជាមុន។



កិច្ចត្រការងារ ឆ្នាំទី២ លេខ០១០ ចេញផ្សាយប្រចាំខែឧសភា ឆ្នាំ២០១២

# វិធីក្នុងការស្វែងយល់អំពីតថភាព

នៅក្នុងបរិយាកាសនៃការបំពេញការងារ បញ្ហាអាចកើតមានឡើងចំពោះអ្វីដែលប្លែក និងអ្វីដែលលំបាក។ ការពិត ប្រសិនអ្វីៗទាំងអស់ដំណើរការទៅដោយរលូន និងមានសភាពរៀបរយទៅតាមផែនការដែលបានគ្រោងទុក នោះទំនងជាអ្នកមានអារម្មណ៍ស្ងប់ស្ងាត់ និងមានទំនុកចិត្ត។ ផ្ទុយទៅវិញ ប្រសិនបើបញ្ហានានាបានកើតមានឡើង នោះអ្នកប្រហែលជាមិនអាចដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធ - ភាពដូចអ្វីដែលអ្នកប្រាថ្នាចង់បាន អាស្រ័យដោយផលវិបាក និងភាពងាយរងគ្រោះរបស់អ្នក។

ឧទាហរណ៍ ថៅហ្វាយនាយរបស់អ្នកបានពោលឡើងថា របាយការណ៍ដែលអ្នកបានរៀបចំគឺមិនមានខ្លឹមសារស្របទៅតាមអ្វីដែលគាត់ (ថៅហ្វាយ) ចង់បានទាល់តែសោះ។ ប្រសិនជាដូច្នោះ តើអ្នកគិតយ៉ាងម៉េច? តើអ្នកនឹងសរសេរអ៊ីម៉េលទៅជជែកតវ៉ា និងការចោទប្រកាន់ឬយ៉ាងណា? ឬអ្នកសម្ងំធ្វើការប្រកបដោយភាពអៀនខ្មាស់ ភាពឈឺចាប់ និងការបារម្ភ ប៉ុន្តែមិនបានសាកសួររកចំណុចសម្រាប់ការកែលំអ? ឬអ្នកញញឹមទទួលយកនូវការណែនាំ ដើម្បីគ្រាន់តែជាការបំពេញមុខមួយពេលប៉ុណ្ណោះ?

ជាការជាក់ស្ដែង រាល់ប្រតិកម្ម និងទង្វើបែបនេះរបស់អ្នក គឺមិនបានបង្ហាញពីការយកចិត្តទុកដាក់ពិតប្រាកដដែលចង់ធ្វើឱ្យការងារបានល្អប្រសើរនោះឡើយ។ ត្រូវចងចាំថា នៅមុនពេលដែលអ្នកប្រែក្លាយដំណោះស្រាយល្អឱ្យធ្លាក់ទៅក្នុងស្ថានភាពអាក្រក់ អ្នកគួរតែគិតទៅដល់ «**តថភាព**» ដែលមាននៅក្នុងស្ថានភាពនោះ។

អ្នកគួរបន្ធូរបន្ថយឥរិយាបថ និងប្រតិកម្មដែលមិនសមហេតុសមផល ឬពោលម្យ៉ាងទៀតថា អ្នកគួរសិក្សាវិភាគអំពីស្ថានភាព បន្ទាប់មកពិនិត្យសម្រេចនូវបញ្ហានោះ តើអ្នកកំពុងជួបប្រទះសត្វខ្លា ឬក៏គ្រាន់តែជាស្រមោលរបស់សត្វឆ្មា? តាមរយៈវិធីនេះ អ្នកអាចគ្រប់គ្រងស្ថានការណ៍ដោយប្រពៃ និងដោយពុំចាំបាច់ចំណាយកម្លាំងកាយ កម្លាំងប្រាជ្ញាច្រើន។

លទ្ធផលដ៏ប្រសើរបំផុត គឺអ្នកត្រូវឆ្លើយតបទៅនឹងស្ថានភាពនោះដោយគំនិតដ៏ឈ្លាសវៃ ដែលមានសភាពត្រឹមត្រូវទាំងការពាក់ព័ន្ធផ្នែកនយោបាយ ការសម្របសម្រួលក្នុងបរិបទការងារ ការបង្កើនលទ្ធផល ឬគោលបំណងរបស់អ្នក និងការដែលមិនបង្កការរារាំង ឬធ្វើទុកបុកម្នេញដល់បុគ្គលិកដទៃ ដែលគេនិយមហៅថា វិធី «**ឈ្នះ-ឈ្នះ**» ។

ដូច្នេះ នៅក្នុងកិពកការងារ បុគ្គលិក ឬនិយោជិតត្រូវរៀនស្វែងយល់ពី «តថភាព» ដែលអាចកើតមាននៅក្នុងកន្លែងការងាររបស់ខ្លួនម្នាក់ៗ ដើម្បីជាប្រយោជន៍ក្នុងការសម្របខ្លួន ការឆ្លើយតបទៅនឹងបញ្ហា ការដោះស្រាយការងារឱ្យទទួលជោគជ័យ និងការចៀសវាងឱ្យបាននូវរាល់កំហុស ឬវិវាទជាមួយបុគ្គលិកដទៃក្នុងវង្វង់ការងារជាមួយគ្នា។

ការស្វែងយល់ពីតថភាពក៏សំដៅទៅដល់ការដែលអ្នកបំពេញការងារអាចដឹងពីលទ្ធភាព និងបទពិសោធន៍របស់អ្នកដែលអាចយកមកប្រើប្រាស់ឱ្យត្រូវតាមស្ថានភាព និងកាលៈទេសៈ ដោយពុំចេះតែគិតស្មានមើលស្រាលស្ថានការណ៍ ឬយល់ខុសចំពោះការពិតនានា ដែលពុំមែនកើតឡើងដូចការគិតរំពឹងទុកនោះឡើយ៕



# ទំនួលខុសត្រូវនៃកិច្ចសន្យាការងារ

## ទំនួលខុសត្រូវរបស់និយោជកចំពោះលក្ខខណ្ឌទូទៅ នៃការងារ

លិខិតបទដ្ឋានគតិយុត្ត

អនុលោមតាមគោលការណ៍នៃកិច្ចសន្យា គឺជាច្បាប់របស់គូភាគី។ ដូចនេះ កិច្ចសន្យាមួយមានសុពលភាពបានបង្កើតនូវអានុភាពគតិយុត្តចំពោះគូភាគីជាកម្លាំងចាប់បង្ខំតាមផ្លូវច្បាប់ឱ្យគូភាគីត្រូវតែប្រតិបត្តិដោយប្រែប្រួលទៅតាមប្រភេទផ្សេងៗនៃកិច្ចសន្យា។ អនុវត្តដូចគ្នាចំពោះកិច្ចសន្យាការងារសុពល ក្នុងនោះគូភាគីទាំងសងខាងនៃកិច្ចសន្យាក្រៅពីការប្រតិបត្តិកិច្ចសន្យា គឺមិនទាមទារឱ្យមានការទទួលខុសត្រូវផ្សេងៗគ្នា ដែលស្តែងចេញពីទង្វើមិនប្រតិបត្តិមិនពេញលេញ ការធ្វេសប្រហែសដែលកើតមានចំពោះលក្ខខណ្ឌទូទៅ និងដោយឡែកនៃការងារ។

### តើអ្វីទៅជាទំនួលខុសត្រូវរបស់និយោជកចំពោះលក្ខខណ្ឌទូទៅ និងដោយឡែកនៃការងារ?

ជាទូទៅកិច្ចសន្យាការងារ គឺជាការព្រមព្រៀងដែលបង្កើតឡើងរវាងភាគីពីរ មានភាគីម្ខាងជា និយោជក ឬភាគីចៅហ្វាយនាយ និងភាគីម្ខាងទៀតជានិយោជិត ឬជាភាគីកូនចៅ ក្នុងនោះភាគីនិយោជិត បានសន្យាថាបំពេញការងារជូននិយោជកក្នុងនាមនិយោជក ដើម្បីផលប្រយោជន៍និយោជក ដោយប្តូរមកវិញនូវប្រាក់កម្រៃប្រចាំខែ។ ផ្អែកតាមនិយមន័យនេះ ទំនួលខុសត្រូវដែលមាន គឺការប្រតិបត្តិការងារដោយនិយោជិត និងការផ្តត់ផ្គង់នូវប្រាក់កម្រៃចំពោះភាគីកូនចៅដែលជាបន្ទុករបស់និយោជក។



ដូចនេះ ទំនួលខុសត្រូវចំពោះលក្ខខណ្ឌទូទៅនិងដោយឡែកនៃការងារ គឺជាការទទួលខុសត្រូវដែលកើតចេញពីកិច្ចសន្យាការងារជាបន្ទុករបស់ភាគីនិយោជក និងនិយោជិតដែលត្រូវបំពេញឆ្លើយតបទៅតាមប្រភេទ និងលក្ខខណ្ឌនៃការងារទូទៅ និងដោយឡែកនៃកិច្ចសន្យាការងារ។



*អត្ថបទរៀបចំ និងដកស្រង់ចេញពីឯកសារច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា ដោយលោក **សុខុន ដារីដ** (អនុប្រធានផ្នែកប្រមូល និងផ្សព្វផ្សាយនៃទីភ្នាក់ងារជាតិមុខរបរ និងការងារ) និងលោកស្រី **ប៉ូលី បញ្ញា** (គ្រូបង្រៀនកម្រិតឧត្តមនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច)។*

តទៅទំព័របន្ទាប់

ព្រឹត្តិបត្រការងារ ឆ្នាំទី២ លេខ០១០ ចេញផ្សាយប្រចាំខែឧសភា ឆ្នាំ២០១២

## ទំនួលខុសត្រូវរបស់ភាគីនិយោជកចំពោះលក្ខខណ្ឌទូទៅនៃកិច្ចសន្យាការងារ

បើធ្វើការវិភាគអំពីវត្ថុបំណងនិងកម្មវត្ថុរបស់ភាគីក្នុងការបង្កើតកិច្ចសន្យាការងារ នោះយើងសង្កេតឃើញថាភាគីមានតម្រូវការរៀងខ្លួន និងមានឆន្ទៈត្រូវគ្នាក្នុងការសម្រេចបង្កើតកិច្ចសន្យាការងារ។ និយោជកត្រូវការឱ្យមាននូវការផ្តត់ផ្គង់សេវាការងារ និងភាគីកូនចៅ ឬនិយោជិតត្រូវការប្រាក់កម្រៃ ដើម្បីបម្រើសេចក្តីត្រូវការផ្ទាល់ខ្លួនដែលជាថ្នូរទៅនឹងការបំពេញសេវាការងារជូនភាគីចៅហ្វាយនាយ។

ដូចនេះ ករណីដែលកូនចៅឬនិយោជិតបានប្រើប្រាស់អស់កម្លាំងកាយកម្លាំងចិត្ត និងកម្លាំងប្រាជ្ញា ដើម្បីបំពេញការងារជូនភាគីនិយោជិក និយោជកមានកាតព្វកិច្ចត្រូវផ្តល់ប្រាក់កម្រៃជូននិយោជិតតាមការសន្យានៃកិច្ចសន្យាការងារ។ ទាំងនេះគឺជាទំនួលខុសត្រូវរបស់និយោជកចំពោះលក្ខខណ្ឌទូទៅនៃ កិច្ចសន្យាការងារ ប៉ុន្តែបញ្ហាចោទថាតើនិយោជកគួរផ្តល់ប្រាក់កម្រៃកម្រិតណាទើបសមរម្យ សមស្របទៅនឹងការផ្គត់ផ្គង់នូវសេវាការងាររបស់ភាគីកូនចៅ។



### ❖ ទំនួលខុសត្រូវរបស់និយោជកចំពោះការកំណត់ប្រាក់ឈ្នួល

អនុលោមតាមមាត្រា ១០២ នៃច្បាប់ការងារ ប្រាក់ឈ្នួលគឺជាឈ្នួលការងារ ឬឈ្នួលសេវាដែលអាចគិតជាប្រាក់បាន ឬកម្រិតបានដោយការព្រមព្រៀងគ្នា ឬដោយច្បាប់ជាតិ ហើយនិយោជកត្រូវបើកឱ្យកម្មករនិយោជិតតាមកិច្ចសន្យាជួលការងារ ឬសេវាដោយលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ទទេ ទោះចំពោះការងារដែលបានធ្វើក្តី ឬដែលត្រូវធ្វើក្តីចំពោះសេវាដែលបានបំពេញ ឬត្រូវបំពេញក្តី។

មានន័យថា ស្របតាមលក្ខខណ្ឌទូទៅនៃកិច្ចសន្យាការងារនិយោជកមិនអាចលើកមូលហេតុ ដើម្បីបដិសេធក្នុងការមិនផ្តល់ប្រាក់ឈ្នួលដល់ភាគីនិយោជិតដែលបានប្រឹងប្រែងអស់កម្លាំងកាយ កម្លាំងចិត្ត និងកម្លាំងប្រាជ្ញា ដើម្បីផ្គត់ផ្គង់នូវសេវាការងារជូននិយោជកក្នុងនាមនិយោជក និងដើម្បីផលប្រយោជន៍និយោជកនោះទេ។ ផ្ទុយទៅវិញ ការបដិសេធអាចធ្វើបានក្នុងករណីដែលកូនឈ្នួល ឬភាគីនិយោជិតមានកំហុសធ្ងន់ធ្ងរ ក្រៅពីនេះ និយោជកគ្មានមូលហេតុផ្សេងក្នុងការបដិសេធមិនព្រមផ្តល់នូវប្រាក់ឈ្នួលជូនដល់ភាគីនិយោជិតទេ។

លើសពីនេះទៅទៀត និយោជកត្រូវបញ្ញត្តិទុកជាមុននូវលក្ខខណ្ឌការងារ និងប្រាក់កម្រៃដែលត្រូវផ្គត់ផ្គង់ចំពោះភាគីនិយោជកទៅតាមប្រភេទការងារផ្សេងៗ ឆ្លើយតបទៅនឹងសកម្មភាពការងារមានជាអាទិ៍ដូចមានចែងក្នុងមាត្រា ១០៣នៃច្បាប់ការងារ។[1] ក្រៅពីនេះ និយោជិតត្រូវបញ្ញត្តិបន្ថែមអំពីគោលការណ៍លើកទឹកចិត្តចំពោះលក្ខខណ្ឌការងារដែលបានបំពេញដោយនិយោជិត។



### ❖ ទំនួលខុសត្រូវរបស់និយោជកចំពោះប្រាក់ឈ្នួលអតិប្បរមាដែលត្រូវធានា

អនុលោមតាមបទប្បញ្ញត្តិស្ដីពីការងារខ្មែរ និយោជកមិនអាចអនុវត្តសិទ្ធិក្នុងការកំណត់នូវប្រាក់ឈ្នួលទាបហួសហេតុ ដែលមានធានាចំពោះលក្ខខណ្ឌជីវិតរបស់និយោជិត ឬកម្មករនិយោជិតបានទេ ពោលគឺប្រាក់ឈ្នួលយ៉ាងតិចណាស់ក៏ត្រូវឱ្យស្មើនឹងប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានារ៉ាប់រងកម្មករនិយោជិតគ្រប់រូបឱ្យមានកំពស់ជីវភាពសមរម្យទៅតាមសេចក្ដីថ្លៃថ្នូរបស់មនុស្ស។[2]

លើសពីនេះទៅទៀត និយោជកមានកាតព្វកិច្ចត្រូវអនុវត្តគោលការណ៍មិនរើសអើងចំពោះភាគី និយោជិត កម្ម-ករនិយោជិតលើគ្រប់រូបភាពចំពោះលក្ខខណ្ឌការងារ ភាពប៉ិនប្រសប់ខាងវិជ្ជាជីវៈ និងផលដែលធ្វើបានស្មើគ្នា ប្រាក់ឈ្នួលត្រូវឱ្យស្មើគ្នាដល់កម្មករនិយោជិតទាំងអស់ទោះបីជាមានដើម កំណើត ភេទ ឬអាយុយ៉ាងណាក៏ដោយ។[3]



### ❖ ទំនួលខុសត្រូវរបស់និយោជិតចំពោះការធានា និងឯកសិទ្ធិនៃប្រាក់ឈ្នួលដែលនៅជំពាក់

និយោជកមានកាតព្វកិច្ចធានាចំពោះការទូទាត់ប្រាក់ឈ្នួលទៅសហគ្រិនទទួលការ ដោយមិនអាចឃាត់ទុក ឬជំទាស់បានឡើយដែលនាំឱ្យខូចប្រាក់ឈ្នួល ឬយឺតយ៉ាវពេលវេលាក្នុងការបើកប្រាក់ឈ្នួលដល់និយោជិត ឬកម្មករនិយោជិត។

ម្យ៉ាងវិញទៀត និយោជកមានកាតព្វកិច្ចត្រូវបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតនូវរាល់មុនការទូទាត់បំណុលផ្សេងៗ។[4]

### ❖ ទំនួលខុសត្រូវរបស់និយោជកចំពោះការកាត់ប្រាក់ឈ្នួល

និយោជិត កម្មករនិយោជិតត្រូវទទួលបាននូវការការពារចំពោះរាល់ការកាត់ប្រាក់ឈ្នួលដោយមិនមានមូលហេតុសមស្រប ដូចជាការកាត់ប្រាក់ឈ្នួលក្នុងគោលបំណងឱ្យអ្នកទទួលរកការងារឱ្យធ្វើ ទោះបីជាសកម្មភាពទាំងនោះធ្វើឡើងដោយផ្ទាល់ ឬដោយប្រយោលក្ដីត្រូវហាមឃាត់។[5] ក្រៅពីនិយោជិតក៏ទទួលបាននូវការការពារផ្សេងទៀត

---

❶មាត្រា១០៣នៃច្បាប់ការងារ បានចែងថាប្រាក់ឈ្នួលមានជាអាទិ៍ដូចតទៅ៖
- ប្រាក់ឈ្នួលសុទ្ធសាធ
- ប្រាក់បន្ថែមម៉ោង
- កំរៃជើងសារ
- បុព្វលាភ និងប្រាក់បំណាច់
- ភាគកម្មក្នុងប្រាក់ចំណេញ
- ប្រាក់ដែលបើកជារង្វាន់
- តំលៃអត្ថប្រយោជន៍ជាវត្ថុ
- វិភាជន៍គ្រួសារសំរាប់ភាគីដែលលើសពីទឹកប្រាក់ត្រឹមត្រូវតាមច្បាប់
- វិភាជន៍សំរាប់ការឈប់សម្រាក ឬបំណាច់សំរាប់ទូទាត់ការឈប់សំរាក
- ចំនួនទឹកប្រាក់ដែលនិយោជកត្រូវផ្ដល់ឲ្យក្នុងពេលបាត់បង់សមត្ថភាពពលកម្ម

និក្នុងពេលលំហែមាតុភាពមិនត្រូវរាប់បញ្ចូលជាមួយប្រាក់ឈ្នួល៖
- ភាពការព្យាបាលសុខ
- វិភាជន៍គ្រួសារតាមច្បាប់
- សោហ៊ុយធ្វើដំណើរ
- អត្ថប្រយោជន៍ដែលផ្ដល់ឲ្យជាពិសេសចំពោះកម្មករនិយោជិតដើម្បីសំរួលការបំពេញមុខងារ

❷មាត្រា១០៤នៃច្បាប់ការងារ

❸មាត្រា១០៥នៃច្បាប់ស្ដីពីការងារ

❹មាត្រា១២១,១២២,១២៤ នៃច្បាប់ស្ដីពីការងារ។

❺មាត្រា១២៦នៃច្បាប់ការងារ។

ចំពោះការទូទាត់ដែលធ្វើឡើង ដើម្បីជាប្រយោជន៍ដល់ភាគីនិយោជករវាងប្រាក់ឈ្នួលដែលត្រូវបើកឲ្យកម្មករនិយោជិត និងប្រាក់ឈ្នួលដែលកម្មករនិយោជិតត្រូវសងទៅនិយោជក ចំពោះការផ្គត់ផ្គង់សំភារៈផ្សេងៗ។ ប៉ុន្តែ និយោជិតអាចអនុវត្តវិធានការទូទាត់ និងការកាត់ប្រាក់ឈ្នួលក្នុងករណីមួយចំនួន ដូចជាការផ្គត់ផ្គង់គ្រឿងប្រដាប់ប្រដា និងឧបករណ៍ចាំបាច់សម្រាប់ការងារដែលកម្មករនិយោជិតមិនបានប្រគល់ឱ្យវិញ នៅពេលឈប់ធ្វើការ វត្ថុធាតុដើម និងសម្ភារៈដែលកម្មករនិយោជិតទទួលបន្ទុក និងប្រើប្រាស់ និងករណីមួយចំនួនទៀតដូចមានចែងក្នុងមាត្រា ១២៧ នៃច្បាប់ការងារ។

ក្រៅពីនេះ ក្នុងករណីដែលនិយោជកបើកប្រាក់ឈ្នួលឱ្យកម្មករនិយោជិតខ្ចីមុន និយោជកអាចអនុវត្តនីតិវិធីកាត់សងរំលោះក្នុងភាគប្រាក់ដែលអាចផ្ទេរ ឬរឹបអូសបាន និងលើកលែងដែលអនុវត្តចំពោះអនុសញ្ញារួមដែលអនុញ្ញាតឱ្យដកហូតលើប្រាក់ឈ្នួល។[6]

## ❖ ទំនួលខុសត្រូវរបស់និយោជកចំពោះប្រាក់ធនានុគ្រោះ

អនុលោមតាមមាត្រា ១៣៤ នៃបទប្បញ្ញត្តិស្តីពីការងារប្រាក់ធនានុគ្រោះ គឺជាកម្រៃដែលអតិថិជនឲ្យទៅបុគ្គលិកនៃសហគ្រាស ឬគ្រឹះស្ថានខ្លះដូចជាសណ្ឋាគារ ភោជនីយដ្ឋាន ផ្ទះកាហ្វេ ផ្ទះលក់ភេសជ្ជៈ ផ្ទះសម្រាប់កាត់សក់ ជាដើម ហើយដែលនិយោជកបានទទួលភាគរយដែលត្រូវបន្ថែមលើកំណត់ទារប្រាក់ពីអតិថិជនក្រោមចំណារសំគាល់សម្រាប់សេវា។ ប្រាក់ធនានុគ្រោះនេះនិយោជកត្រូវប្រមូល ហើយបើកឱ្យបុគ្គលិកដែលទាក់ទងទៅនឹងអតិថិជនវិញទាំងអស់។

## ❖ ទំនួលខុសត្រូវរបស់និយោជកចំពោះថិរវេលាធ្វើការ ថិរវេលាប្រចាំថ្ងៃ និងប្រចាំសប្តាហ៍

អនុលោមតាមបទប្បញ្ញត្តិស្តីពីការងារក្នុងគ្រឹះស្ថានប្រភេទណាក៏ដោយ ទោះបីជាគ្រឹះស្ថាននោះមានលក្ខណៈជាការសិក្សាវិជ្ជាជីវៈ ឬជាកិច្ចកុសលព្រមទាំងនៅក្នុងវិជ្ជាជីវៈសេរីក៏ដោយ ថិរវេលាធ្វើការពេញលេញនៃកម្មករនិយោជិតទាំងពីភេទមិនត្រូវឱ្យលើសពី៨ម៉ោងក្នុងមួយថ្ងៃ ឬ ៤៨ម៉ោងក្នុង មួយអាទិត្យឡើយ និងក្នុងករណីដែលមានកិច្ចការប្រញាប់ខុសធម្មតាតម្រូវនិយោជិតធ្វើការបន្ថែមម៉ោងក្រៅម៉ោងពេលធម្មតា ម៉ោងពេលបន្ថែមទាំងនោះត្រូវ។[7]

[6] មាត្រា១២៨ និង១២៩នៃច្បាប់ការងារ
[7] មាត្រា១៣៧, ១៣៨, ១៣៩នៃច្បាប់ការងារ។





ព័ត៌មានទីផ្សារការងារ

# ព័ត៌មានទីផ្សារការងារនៅកម្ពុជា

## ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក ដែលបានប្រមូលដោយ ទីភ្នាក់ងារជាតិមុខរបរ និងការងារពី ខែមីនា ឆ្នាំ២០១០ ដល់ ខែឧសភា ឆ្នាំ២០១២

អត្ថបទនេះមានបំណងបង្ហាញពីតម្រូវការ និងការផ្គត់ផ្គង់កម្លាំងពលកម្មក្នុងពេលបច្ចុប្បន្ន នៅក្នុងទីផ្សារការងារកម្ពុជាតាមរយៈទិន្នន័យស្ថិតិអ្នកចុះឈ្មោះស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក ដែលបានប្រមូលដោយទីភ្នាក់ងារជាតិមុខរបរ និងការងារចាប់ពីខែមីនា ឆ្នាំ២០១០ ដល់ខែមេសា ឆ្នាំ២០១២។ ទិន្នន័យទាំងអស់នោះរួមមាន អ្នកចុះឈ្មោះស្វែងរកការងារធ្វើចំនួន ៩.២៦១នាក់ (មិនរួមបញ្ចូលអ្នកស្វែងរកការងារធ្វើដែលបានប្រមូលនៅតាមមូលដ្ឋាន) និងព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ៦៨.០២២នាក់។ ជាថ្មីម្តងទៀត ទ.ជ.ម.ក សូមបញ្ជាក់ថា ទិន្នន័យដែលបាន និងកំពុងលើកយកមកបង្ហាញជូនក្នុងផ្នែកនេះ គឺមិនគ្របដណ្តប់លើទិន្នន័យសម្រាប់ប្រទេសកម្ពុជាទាំងមូលទេ ដូច្នេះរាល់ការប្រើប្រាស់ និងបកស្រាយទិន្នន័យទាំងនេះ សូមយកមកពិចារណានូវបញ្ហានេះ។

### ១. ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមក្រុមចំណាត់ថ្នាក់មុខរបរ (ខែមីនា ឆ្នាំ២០១០ - ខែមេសា ឆ្នាំ២០១២)

ដើម្បីធ្វើការបង្ហាញ អំពីស្ថានភាពទីផ្សារការងារមួយ យើងចាំបាច់ត្រូវតែធ្វើការពិចារណាទៅលើតម្រូវការ និងការផ្គត់ផ្គង់នៃកម្លាំងពលកម្មនៅក្នុងទីផ្សារនេះ។ ប៉ុន្តែការវិភាគ ពិចារណាពីកម្លាំងពលកម្មអាចធ្វើឡើងក្នុងទម្រង់ និងរូបភាពច្រើនសណ្ឋាន។ ក្នុងចំនុចនេះ ទីភ្នាក់ងារជាតិមុខរបរ និងការងារ (ទ.ជ.ម.ក) សូមលើកយកការប្រៀបធៀបរវាងចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក ដោយបែងចែកតាមក្រុមចំណាត់ថ្នាក់មុខរបរ (ISCO) មកធ្វើការបង្ហាញជូន។ បើពិនិត្យមើលទៅលើក្រុមចំណាត់ថ្នាក់មុខរបរធំបំផុត (Major Group) ដែលបានបង្ហាញជូនក្នុងរូបទី១ ខាងក្រោមឃើញថា ក្រុមដែលមានការផ្គត់ផ្គង់កម្លាំងពលកម្មច្រើនជាងគេ គឺក្រុមអ្នកជំនាញឯកទេសវិជ្ជាជីវៈ ដែលមានអត្រារហូតដល់៣១,៩% នៃចំនួនអ្នកស្វែងរកការងារធ្វើសរុបដែលប្រមូលដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ ចំណែកតម្រូវការកម្លាំងពលកម្មសម្រាប់ក្រុមជំនាញដូចគ្នានេះ គឺមានត្រឹមតែ១៤,៣% ប៉ុណ្ណោះ។ បើពិនិត្យមើលទៅលើផ្នែកតម្រូវការកម្លាំងពលកម្មវិញ ឃើញថាក្រុមដែលមានតម្រូវការខ្ពស់ជាងគេ គឺកម្មករជំនាញផ្នែកសិប្បកម្ម និងកិច្ចការជំនួញផ្សេងៗ ដែលមានអត្រារហូតដល់ ៣៨,៦% នៃតម្រូវការកម្លាំងពលកម្មសុរប ដែលបានប្រមូលដោយ ទ.ជ.ម.ក រីឯការផ្គត់ផ្គង់សម្រាប់ក្រុមចំណាត់ថ្នាក់មុខរបរដូចគ្នានេះមានត្រឹមតែ១២,០% ប៉ុណ្ណោះ។

រូបទី១ ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមក្រុមចំណាត់ថ្នាក់មុខរបរ ISCO (ខែមីនា ឆ្នាំ២០១០ - ខែមេសា ឆ្នាំ២០១២)




សម្គាល់៖ អ្នកស្វែងរកការងារធ្វើសរុបចំនួន ៩.២៦១នាក់ និងព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ៦៨.០២២នាក់

## ២. ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមចំណាត់ថ្នាក់សហគ្រាសនៃសកម្មភាពសេដ្ឋកិច្ច (ខែមីនា ឆ្នាំ២០១០ - ខែមេសា ឆ្នាំ២០១២)

បើពិនិត្យមើលទៅលើចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក ដោយបែងចែកទៅតាមវិស័យធំៗទាំងបីនៃសកម្មភាពសេដ្ឋកិច្ច យើងចាប់អារម្មណ៍ឃើញថា ទាំងតម្រូវការ និងការផ្គត់ផ្គង់កម្លាំងពលកម្ម គឺបានប្រមូលផ្តុំនៅក្នុងវិស័យសេវាកម្ម និងតាមពីក្រោយរៀងគ្នាដោយវិស័យឧស្សាហកម្ម និងកសិកម្ម។ ក្នុងនោះ យើងសង្កេតឃើញថា នៅក្នុងវិស័យសេវាកម្ម ចំនួនអ្នកស្វែងរកការងារធ្វើ(ផ្នែកផ្គត់ផ្គង់កម្លាំងពលកម្ម) មានអត្រា៧៥,៦% ខ្ពស់ជាងព័ត៌មានជ្រើសរើសបុគ្គលិក(ផ្នែកតម្រូវការកម្លាំងពលកម្ម)ដែលមានអត្រា៥៤,១% ប៉ុណ្ណោះ។ ចំណែកឯវិស័យឧស្សាហកម្មវិញ ឃើញថាព័ត៌មានជ្រើសរើសបុគ្គលិក(ផ្នែកតម្រូវការកម្លាំងពលកម្ម)មានអត្រាប្រហែល៤៥,៣% ចំណែកឯចំនួនអ្នកស្វែងរកការងារធ្វើ (ផ្នែកផ្គត់ផ្គង់កម្លាំងពលកម្ម) ក្នុងវិស័យនេះវិញ មានអត្រាត្រឹមតែ២២,៣%ប៉ុណ្ណោះ។

រូបទី២ ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក បែងចែកតាមវិស័យសេដ្ឋកិច្ច (ខែមីនា ឆ្នាំ២០១០ ខែមេសា ឆ្នាំ២០១២)

សម្គាល់៖ អ្នកស្វែងរកការងារធ្វើសរុបចំនួន ៩.២៦១នាក់ និងព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ៦៨.០២២នាក់





តទៅទំព័របន្ទាប់

## តារាងទី១ ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមចំណាត់ថ្នាក់សហគ្រាសនៃសកម្មភាពសេដ្ឋកិច្ច (ខែមីនា ឆ្នាំ២០១០ - ខែមេសា ឆ្នាំ២០១២)

| | ចំណាត់ថ្នាក់នៃសហគ្រាស | អ្នកស្វែងរកការងារធ្វើ | | ព័ត៌មានជ្រើសរើសបុគ្គលិក | |
|---|---|---|---|---|---|
| | | ចំនួន | ភាគរយ (%) | ចំនួន | ភាគរយ (%) |
| A | កសិកម្ម និងរុក្ខាប្រមាញ់ | 195 | 2.1 | 403 | 0.6 |
| B | រ៉ែ និងថ្ម | 11 | 0.1 | 9 | 0.0 |
| C | កម្មន្តសាល | 1155 | 12.5 | 29378 | 43.2 |
| D | អគ្គិសនី ឧស្ម័ន ចំហាយ និងផ្គត់ផ្គង់ម៉ាស៊ីនត្រជាក់ | 632 | 6.8 | 597 | 0.9 |
| E | ផ្គត់ផ្គង់ទឹក លូទឹក គ្រប់គ្រងសំរាម និងសកម្មភាពផ្សេងៗ | 34 | 0.4 | 16 | 0.0 |
| F | សំណង់ | 237 | 2.6 | 785 | 1.2 |
| G | លក់ដុំ និងរាយ | 912 | 9.8 | 5008 | 7.4 |
| H | ដឹកជញ្ជូន ស្តុក និងឃ្លាំង | 95 | 1.0 | 258 | 0.4 |
| I | សណ្ឋាគារ ការស្នាក់អាស្រ័យ អាហារ ភេសជ្ជៈ និងសេវាផ្សេងៗ | 743 | 8.0 | 5868 | 8.6 |
| J | ព័ត៌មាន និងទូរគមនាគមន៍ | 678 | 7.3 | 1869 | 2.7 |
| K | ហិរញ្ញវត្ថុ និងធានារ៉ាប់រង | 1788 | 19.3 | 2019 | 3.0 |
| L | អចលនទ្រព្យ | 22 | 0.2 | 196 | 0.3 |
| M | វិជ្ជាជីវៈ បច្ចេកទេស និងវិទ្យាសាស្ត្រ | 698 | 7.5 | 1058 | 1.6 |
| N | រដ្ឋបាល និងសេវាគាំទ្រ | 337 | 3.6 | 1844 | 2.7 |
| O | រដ្ឋបាលសាធារណៈ និងការពារ | 158 | 1.7 | 617 | 0.9 |
| P | អប់រំ | 560 | 6.0 | 7031 | 10.3 |
| Q | សុខភាព និងសេវាសង្គម | 144 | 1.6 | 2688 | 4.0 |
| R | សិល្បៈ ការកំសាន្ត និងការច្នៃប្រឌិត | 37 | 0.4 | 1170 | 1.7 |
| S | សេវាផ្សេងៗ | 684 | 7.4 | 6460 | 9.5 |
| T | សកម្មភាពជានិយោជកនៅក្នុងផ្ទះដោយប្រកបអាជីវកម្ម ឬសេវាផ្សេងៗ | 14 | 0.1 | 63 | 0.1 |
| U | សកម្មភាពរបស់ស្ថានទូត កុងស៊ុល និងអង្គការអន្តរជាតិ | 128 | 1.4 | 682 | 1.0 |
| | សរុប | 9261 | 100.0 | 68022 | 100.0 |

សម្គាល់៖ អ្នកស្វែងរកការងារធ្វើសរុបចំនួន ៩.២៦១នាក់ និងព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ៦៨.០២២នាក់

តទៅទំព័របន្ទាប់

## ៣. ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមកម្រិតអប់រំ (ខែមីនា ឆ្នាំ២០១០ - ខែមេសា ឆ្នាំ២០១២)

ដោយផ្អែកលើទិន្នន័យ នៃចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក ដែលបានប្រមូលដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ ដោយបែងចែកតាមកម្រិតអប់រំ (រូបទី៣ និងតារាងទី២) ឃើញថាអ្នកស្វែងរកការងារធ្វើ (ផ្នែកផ្គត់ផ្គង់កម្លាំងពលកម្ម) មួយភាគធំប្រមាណជា ៦៤,៥% កាន់សញ្ញាបត្របរិញ្ញាបត្រ ចំណែកឯព័ត៌មានជ្រើសរើសបុគ្គលិក (ផ្នែកតម្រូវការកម្លាំងពលកម្ម) កម្រិតបរិញ្ញាបត្រវិញ មានត្រឹមតែ១៧,០% ប៉ុណ្ណោះ។ បើពិនិត្យមើលទៅលើព័ត៌មានជ្រើសរើសបុគ្គលិក (ផ្នែកតម្រូវការកម្លាំងពលកម្ម) វិញ ឃើញថាតម្រូវការកម្លាំងពលកម្មមួយភាគធំ គឺមិនទាមទារឱ្យមានបញ្ចប់ថ្នាក់សិក្សាណាមួយឡើយ ដែលមានអត្រារហូតដល់ ៦០,៥% ដែលជាអត្រាមួយខ្ពស់ខ្លាំង បើប្រៀបធៀបជាមួយនឹងចំនួនអ្នកស្វែងរកការងារធ្វើដែលមានកម្រិតអប់រំដូចគ្នានេះ ដែលមានត្រឹមតែ៩.៩ ប៉ុណ្ណោះ។

រូបទី៣ ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក បែងចែកតាមកម្រិតអប់រំបណ្តុះបណ្តាល (ខែមីនា ឆ្នាំ២០១០ - ខែមេសា ឆ្នាំ២០១២)




សម្គាល់៖ អ្នកស្វែងរកការងារធ្វើសរុបចំនួន ៩.២៦១នាក់ និងព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ៦៨.០២២នាក់

តារាងទី២ ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមកម្រិតអប់រំ (ខែមីនា ឆ្នាំ២០១០ - ខែមេសា ឆ្នាំ២០១២)

| ល.រ | ប្រភេទកម្រិតសិក្សា | អ្នកស្វែងរកការងារធ្វើ | | ព័ត៌មានជ្រើសរើសបុគ្គលិក | |
|---|---|---|---|---|---|
| | | ចំនួន | ភាគរយ (%) | ចំនួន | ភាគរយ (%) |
| ១ | មិនធ្លាប់បានសិក្សាឬបញ្ចប់ថ្នាក់ណាមួយឡើយ | 918 | 9.9 | 41163 | 60.5 |
| ២ | បឋម | 144 | 1.6 | 639 | 0.9 |
| ៣ | អនុវិទ្យាល័យ | 319 | 3.4 | 2791 | 4.1 |
| ៤ | វិទ្យាល័យ | 443 | 4.8 | 3074 | 4.5 |
| ៥ | សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) | 582 | 6.3 | 5670 | 8.3 |
| ៦ | សញ្ញាប័ត្រវិជ្ជាជីវៈរយៈពេលវគ្គខ្លី | 48 | 0.5 | 275 | 0.4 |
| ៧ | សញ្ញាប័ត្របណ្តុះបណ្តាលវិជ្ជាជីវៈកម្រិត I | 6 | 0.1 | 13 | 0.0 |
| ៨ | សញ្ញាប័ត្របណ្តុះបណ្តាលវិជ្ជាជីវៈកម្រិត II | 8 | 0.1 | 0 | 0.0 |
| ៩ | សញ្ញាប័ត្របណ្តុះបណ្តាលវិជ្ជាជីវៈកម្រិត III | 20 | 0.2 | 12 | 0.0 |
| ១០ | សញ្ញាប័ត្របច្ចេកទេស | 145 | 1.6 | 360 | 0.5 |
| ១១ | បរិញ្ញាប័ត្ររង | 516 | 5.6 | 765 | 1.1 |
| ១២ | បរិញ្ញាប័ត្រ | 5970 | 64.5 | 11584 | 17.0 |
| ១៣ | អនុបណ្ឌិត | 111 | 1.2 | 431 | 0.6 |
| ១៤ | បណ្ឌិត | 2 | 0.0 | 623 | 0.9 |
| ១៥ | សញ្ញាប័ត្របញ្ជាក់វិជ្ជាជីវៈ/អាជ្ញាបណ្ណ/កម្រិត | 29 | 0.3 | 622 | 0.9 |
| | សរុប | 9261 | 100.0 | 68022 | 100.0 |

សម្គាល់៖ អ្នកស្វែងរកការងារធ្វើសរុបចំនួន ៨.៦៩៥នាក់ និងព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ៥៥.៤៦២នាក់

ព័ត៌មានទីផ្សារការងារជាកោសិកានៃការអភិវឌ្ឍ!




# មុខរបរទាំងដប់ដែលមានតម្រូវការខ្លាំងក្នុង
# Top Ten Occupations ទីផ្សារការងារកម្ពុជា

ការសម្រេចចិត្តក្នុងការចាប់យកនូវជំនាញ ឬអាជីពដែលសមស្របនៅក្នុងទីផ្សារការងារ គឺជាកត្តាមួយដ៏សំខាន់សម្រាប់យុវជន យុវនារី ក្នុងការឈានទៅសម្រេចបាននូវវត្ថុបំណងក្នុងឆាកជីវិតរបស់ពួកគេ។ យើងតែងមានចម្ងល់ថា ហេតុអ្វីបានជាអ្នកស្វែងរកការងារធ្វើមិនទទួលបានការងារធ្វើ នៅពេលមានព័ត៌មានជ្រើសរើសបុគ្គលិក ជាច្រើនបានធ្វើការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ និងតាមបណ្ដាញសង្គមសម្រាប់ក្រុមហ៊ុន ឬសហគ្រាសរបស់ខ្លួន។ ស្ថានភាពទាំងអស់នេះបានបង្ហាញឱ្យឃើញថា ភាពអត់ការងារធ្វើពុំមែនមានន័យថាកង្វះការងារនោះទេ ប៉ុន្តែអាចបណ្ដាលមកពីការងារ និងជំនាញមិនទាន់បន្ស៊ីគ្នាឱ្យបានពេលលេញ កង្វះខាតលំហូរព័ត៌មានស្ដីអំពីតម្រូវការនៅលើទីផ្សារការងារ និងភាពមិនទាន់ស៊ីចង្វាក់ទៅនឹងជំនាញ និងកម្រិតលក្ខណៈសម្បត្តិរបស់អ្នកស្វែងរកការងារធ្វើនៅឡើយ។ ដូច្នេះសម្រាប់ព្រឹត្តិបត្រការងារផ្នែកនេះ ទីភ្នាក់ងារជាតិមុខរបរ និងការងារសូមលើកយកមកបង្ហាញនូវមុខរបរ ដែលមានអាទិភាពចំនួន១០ ក្នុងនោះមានពិពណ៌នាពីការងារអ្វីខ្លះដែលអ្នកគួរធ្វើការអប់រំ និងការបណ្ដុះបណ្ដាល ដែលអ្នកត្រូវសិក្សាដើម្បីទទួលបានតំណែងបែបនោះ ជំនាញ និងសមត្ថភាពដែលគួរមាន និងបុគ្គលិកលក្ខណៈបែបណាដែលស្របទៅនឹងការងារប្រភេទនេះ។











*អត្ថបទនេះដកស្រង់ និងប្រែសម្រួលដោយ **លោក សួង សង្វារិទ្ធី** ប្រធានផ្នែកផែនការ និងសហប្រតិបត្តិការ និង **លោកស្រី លី វួចចេង** អនុប្រធានផ្នែកផែនការ និងសហប្រតិបត្តិការ ចេញពីសៀវភៅ Occupation Outlook Handbook និង Career Discovery Encyclopedia។ សម្រាប់ព័ត៌មានបន្ថែមសូមអញ្ជើញរកអានឯកសារស្ដីពីអាជីព និងការងារដែលមានតម្កល់ទុកនៅក្នុង «**បណ្ណាល័យការងារ**» របស់ទីភ្នាក់ងារជាតិមុខរបរ និងការងារដោយមេត្រី។*


តទៅទំព័របន្ទាប់

NEA
ទីភ្នាក់ងារជាតិមុខរបរ និងការងារ

Top Ten Occupation 1.

# កម្មករជំនាញដេរប៉ាក់

## Sewing, embroidery and related workers



**កម្មករជំនាញដេរ ប៉ាក់ និងការងារដែលពាក់ព័ន្ធ** គឺសំដៅទៅលើអ្នកដែលចេះដេរ ប៉ះ ផុង ប៉ាក់ កែតម្រូវ និងតុបតែងសម្លៀកបំពាក់ ស្រោមដៃ និងផលិតផលនានាដែល ធ្វើពីក្រណាត់ រោមសត្វ ស្បែក និងវត្ថុធាតុដើមផ្សេងទៀត។ ការងារទាំងនេះគឺជាប្រភេទ ការងារហត្ថកម្ម ក៏ប៉ុន្តែមានការងារមួយចំនួនតម្រូវឱ្យប្រើប្រាស់ម៉ាស៊ីនដេរ។

### ការងារ

- ដេរ ប៉ះ ឬកែតម្រូវដោយដៃនូវផ្នែកនៃសម្លៀកបំពាក់ដែលខូចខាតដោយប្រើប្រាស់ម្ជុល និងអំបោះ
- ប្រើប្រដាប់ច្រៀក ឬផ្លែឡាមក្នុងការជួសយកថ្នេរខុសចេញពីសម្លៀកបំពាក់ដើម្បីធ្វើការផ្លាស់ប្តូរថ្មី
- ជ្រើសរើសអំបោះទៅតាមតម្រូវការ ឬពណ៌ដែលត្រូវគ្នាទៅនឹងស្រមោល និងពណ៌ក្រណាត់ដែលត្រូវស្រេះ
- ដេរ ប៉ះ ស្រេះ ឬផុងសម្លៀកបំពាក់ដែលខូតខាត ដូចជាមានប្រហោង តំណរហែក ឬដាច់ថ្នេរ ដោយប្រើប្រាស់ម្ជុល និងអំបោះ
- ប្រើប្រាស់ទំពក់សម្រាប់ទាញចំណងអំបោះនៅខាងក្រោយក្រណាត់ ឬសម្ភារផ្សេងៗ
- ប្រើប្រាស់កន្ត្រៃតម្រឹមក្រណាត់ដែលនៅសល់ខាងចុងឱ្យបានសមរម្យ
- ដេរដានដោយដៃទៅលើក្រណាត់ គំរូពុម្ព ឬក្រដាស់ស្តីនស៊ីលដោយប្រើម្ជុល និងអំបោះពណ៌
- ប៉ាក់ដោយប្រើប្រាស់ម្ជុល និងអំបោះពណ៌លើក្រណាត់គំរូពុម្ពដោយដៃ ឬដោយប្រើម៉ាស៊ីន



- យល់ដឹងពីវិធីសាស្ត្រក្នុងការត្រាំស្បែក ឬសម្ភារស្បែកជើងក្នុងទឹកឱ្យទន់ដើម្បីងាយស្រួលដេរ
- ដេរ ឬបិទការគ្រឿងតុបតែងលើសម្ភារផ្សេងៗដូចជាមួកបុរស ឬស្ត្រីជាដើម។

### ការអប់រំ និងការបណ្តុះបណ្តាល




- កម្រិតសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
- ការបណ្តុះបណ្តាលរយៈពេលខ្លី ឬរយៈពេលវែងដែលទាក់ទងនឹងការដេរ និងប៉ាក់
- មានបទពិសោធន៍ការងារពាក់ព័ន្ធ។

### ជំនាញ និងសមត្ថភាព

- ចេះអាន និងសរសេរភាសាខ្មែរ
- មានជំនាញមូលដ្ឋានគ្រឹះក្នុងការដេរ និងប៉ាក់ជាដើម។

### កាយសម្បទា និងបុគ្គលិកលក្ខណៈ

- មានកាយសម្បទាមាំមួន
- មានទំនួលខុសត្រូវខ្ពស់ និងមានភាពស្មោះត្រង់
- មានអាយុចាប់ពី ១៨ ឆ្នាំឡើង។

### ប្រាក់ឈ្នួល និងប្រាក់ឧបត្ថម្ភ

- ប្រាក់ឈ្នួលជាមធ្យមពី ៦១ - ១០០ ដុល្លាអាមេរិកក្នុងមួយខែ
- ប្រាក់រង្វាន់ និងប្រាក់ឧបត្ថម្ភផ្សេងៗអាស្រ័យទៅតាមការកំណត់របស់ក្រុមហ៊ុន។

សុពលភាពៈ 2011-2012

តទៅទំព័របន្ទាប់

ទីភ្នាក់ងារជាតិមុខរបរ និងការងារ

# Top Ten Occupation 2. កម្មករជំនាញអេឡិចត្រូនិច Electronic workers

**កម្មករជំនាញអេឡិចត្រូនិច** គឺសំដៅទៅលើអ្នកដែលមានជំនាញផ្នែកដំឡើង ជួសជុល និងថែទាំម៉ាស៊ីនអេឡិចត្រូនិចដែលប្រើប្រាស់នៅតាមគ្រឹះស្ថានអាជីវកម្ម និងតាមគេហដ្ឋានដូចជា ម៉ាស៊ីនកុំព្យូទ័រ ទូរទស្សន៍ វិទ្យុ ប្រដាប់បំពងសម្លេង ម៉ាញ៉េ និងឧបករណ៍អេឡិចត្រូនិចដទៃទៀត ។

## ការងារ

- ផ្តល់សេវាជួសជុលជូនអតិថិជនដល់កន្លែង ឬនៅកន្លែងផ្សេងទៀត ដែលត្រូវការជុសជុលជាចាំបាច់
- ធ្វើការជួសជុល ថែទាំ និងដំឡើងឧបករណ៍អេឡិចត្រូនិចនានាដោយប្រើដៃ
- ស្វែងរកប្រភពបញ្ហាដើម្បីធ្វើការជួលជុល និងផ្លាស់ប្តូរនូវផ្នែកដែលខូចខាត ដើម្បីឱ្យម៉ាស៊ីនដំណើរការបានល្អប្រសើរ
- ធ្វើការត្រួតពិនិត្យ និងថែទាំឧបករណ៍អេឡិចត្រូនិចជាប្រចាំ។



## ការអប់រំ និងការបណ្តុះបណ្តាល

- សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
- សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត I ដល់បរិញ្ញាបត្របច្ចេកវិទ្យា/ ឯកទេសផ្នែកអេឡិចត្រូនិច
- មានបទពិសោធន៍ការងារពាក់ព័ន្ធ។




## ជំនាញ និងសមត្ថភាព

- មានការយល់ដឹងអំពីមូលដ្ឋានគ្រឹះក្នុងការថែទាំ និងជួសជុលឧបករណ៍អេឡិចត្រូនិច



- មានចំណេះដឹង និងជំនាញក្នុងការប្រើប្រាស់ឧបករណ៍ដោយដៃដូចជាដង្កាប់ ទួរណឺវីស ម៉ាឡែត ញញួរ កាំបិត ម៉ូទ័រខ្វង ឬស្វានជាដើម
- មានជំនាញទំនាក់ទំនងល្អ និងការបំពេញការងារជាក្រុម
- មានសមត្ថភាពបំពេញការងារក្រោមសម្ពាធ
- មានអាទិភាពខ្ពស់សម្រាប់អ្នកមានចំណេះដឹងផ្នែកភាសាអង់គ្លេស។

## កាយសម្បទា និងបុគ្គលិកលក្ខណៈ:

- មានកាយសម្បទាមាំមួន
- មានទំនួលខុសត្រូវខ្ពស់ និងជឿជាក់លើខ្លួនឯង
- មានភាពស្មោះត្រង់ និងព្យាយាមបំពេញការងារ។

សុពលភាព: 2011-2012

ទីភ្នាក់ងារជាតិមុខរបរ និងការងារ

# Top Ten Occupation 3. កម្មករក្នុងវិស័យកសិកម្ម Agricultural worker

**កម្មករក្នុងវិស័យកសិកម្ម** គឺសំដៅទៅលើអ្នកដែលបម្រើការងារនៅក្នុងចំការ ឬកសិដ្ឋាន។ ការងារចំបងរបស់អ្នកទាំងនោះ គឺធ្វើការដាំដុះ ផ្សាំ ថែទាំដី និងដំណាំ ប្រើប្រាស់ជីធម្មជាតិ និងជីគីមី ដើម្បីឱ្យទទួលបានទិន្នផលកសិកម្មប្រកបដោយគុណភាពខ្ពស់សម្រាប់បញ្ជូនទៅកាន់ទីផ្សារ។

## ការងារ

- ដាំដុះ និងប្រមូលគ្រាប់ធញ្ញជាតិ ផ្លែឈើ បន្លែ និងដំណាំផ្សេងទៀត
- វេចខ្ចប់ និងរៀបចំសម្រាប់នាំចេញ
- បោះបង្គោល ចង រុំ និងរៀបចំដំណាំឱ្យតាមលំដាប់លំដោយ
- ជីក ឬកាយដី និងដាក់កូនឈើទៅក្នុងកំប៉ុង
- ប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត ដកស្មៅ និងដាក់ជី ដាំដំណាំ ជួសជុលរបង និងឧបករណ៍ប្រើប្រាស់នៅក្នុងចំការ ឬកសិដ្ឋាន
- ធ្វើចំណាត់ថ្នាក់ ជ្រើសរើស និងបែងចែកផលិតផលដែលមិនទាន់កែច្នៃ និងផលិតផលកសិកម្មដទៃទៀតទៅតាមទំហំ ទំងន់ ពណ៌ ឬកម្រិត



និងធ្វើការជំរុះចោលនូវផលិតផលដែល មានគុណភាពអន់។

## ការអប់រំ និងការបណ្ដុះបណ្ដាល

- កម្រិតសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ឬមធ្យមសិក្សាទុតិយភូមិ
- ការបណ្ដុះបណ្ដាលរយៈពេលខ្លី និងវែងដែលទាក់ទងទៅនឹងការងារនៅក្នុងវិស័យកសិកម្មមានបទពិសោធន៍ការងារពាក់ព័ន្ធ។



## ជំនាញ និងសមត្ថភាព

- ចេះអាន និងសរសេរភាសាខ្មែរ
- អាចបំពេញការងារជាក្រុម
- មានសមត្ថភាពបំពេញការងារក្រោមសម្ពាធ
- អាចធ្វើការបន្ថែមម៉ោង។

## កាយសម្បទា និងបុគ្គលិកលក្ខណៈ

- មានកាយសម្បទាមាំមួន



- មានទំនួលខុសត្រូវខ្ពស់ និងចេះលើកទឹកចិត្តខ្លួនឯង
- មានភាពឧស្សាហ៍ព្យាយាមក្នុងការបំពេញការងារ និងមានភាពអំណត់។

សុពលភាព: 2011-2012

តទៅទំព័របន្ទាប់

ទីភ្នាក់ងារជាតិមុខរបរ និងការងារ

## Top Ten Occupation 4. សន្តិសុខ Security Guards

**សន្តិសុខ** គឺសំដៅទៅលើអ្នកដែលមានភារកិច្ចដើរយាមល្បាត និងត្រួតពិនិត្យ ដើម្បីការពារ និងថែរក្សាទ្រព្យសម្បត្តិឯកជន ឬសាធារណៈពីក្រុមជនឆ្លៀតឱកាស ឬក្រុមចោរកម្មជាដើម។ ទន្ទឹមនឹងនេះ សន្តិសុខ ក៏ជាអ្នកធ្វើការត្រួតពិនិត្យនៅមាត់ច្រកចេញ-ចូលនៅតាមគ្រឹះស្ថានឯកជន ឬសាធារណៈ និងការពារសណ្តាប់-ធ្នាប់ទូទៅ។

### ការងារ

- ថែរក្សាសណ្តាប់ធ្នាប់ ទ្រព្យសម្បត្តិ ការពារសុវត្ថិភាពបុគ្គលិក និងអតិថិជន
- ការពារសុវត្ថិភាពក្នុងការបញ្ជូនសាច់ប្រាក់ ឬសម្ភារមានតម្លៃទៅកាន់ធនាគារ ឬគ្រឹះស្ថានដទៃទៀត
- យាមល្បាតនៅក្នុងបរិវេណអគារ និងត្រួតពិនិត្យមើលនៅមាត់ច្រកចេញ-ចូល បង្អួច និងរបង ដើម្បីទប់ស្កាត់ និងការពារភាពមិនប្រក្រតី ដែលអាចកើតមានឡើង



- ត្រួតពិនិត្យការចេញ-ចូលរបស់បុគ្គលិក ឬអតិថិជននៅក្នុងគ្រឹះស្ថាន សាកសួរ និងពិនិត្យអត្តសញ្ញាណរបស់អតិថិជន និងផ្តល់បណ្ណអនុញ្ញាតចេញ-ចូល
- ត្រួតពិនិត្យសន្តិសុខតាមរយៈការឆែកឆេរអ្នកធ្វើដំណើរ និងអីវ៉ាន់
- ត្រួតពិនិត្យសញ្ញាប្រកាសអាសន្ន ដោយជូនដំណឹងដល់អ្នកគ្រប់គ្រង របស់ខ្លួន ប៉ូលីស ឬក្រុមពន្លត់អគ្គីភ័យជាដើម
- កត់ត្រាចំនួនអតិថិជនដែលបានចេញ-ចូល ជាប្រចាំ
- ធ្វើការត្រួតពិនិត្យសុវត្ថិភាពនៅកន្លែងធ្វើការជាប្រចាំ។

### ការអប់រំ និងបណ្តុះបណ្តាល

- សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
- ការបណ្តុះបណ្តាលរយៈពេលខ្លី ឬវែងតាមរយៈការអនុវត្តន៍ការងារដោយផ្ទាល់។

### • ជំនាញ និងសមត្ថភាព



- អាចនិយាយ និងសរសេរភាសាខ្មែរ
- អាចបំពេញការងារជាក្រុម
- មានសមត្ថភាពបំពេញការងារក្រោមសម្ពាធ
- អាចធ្វើការបន្ថែមម៉ោង។

### កាយសម្បទា និងបុគ្គលិកលក្ខណៈ:



- មានកាយសម្បទាមាំមួន
- មានទំនួលខុសត្រូវខ្ពស់ និងមានភាពស្មោះត្រង់
- មានជំនាញទំនាក់ទំនងល្អ
- មានអាយុចាប់ពី ១៨ ឡើង។

### ប្រាក់ឈ្នួល និងប្រាក់ឧបត្ថម្ភ

- ប្រាក់ឈ្នួលជាមធ្យមពី ៦០ - ១៥០ ដុល្លាអាមេរិកក្នុងមួយខែ
- ប្រាក់រង្វាន់ និងប្រាក់ឧបត្ថម្ភផ្សេងៗអាស្រ័យទៅតាមការកំណត់របស់ក្រុមហ៊ុន។

សុពលភាព: 2011-2012

ទីភ្នាក់ងារជាតិមុខរបរ និងការងារ

Top Ten Occupation 5.

# ជាងអគ្គិសនី Electricians

**ជាងអគ្គិសនី** គឺសំដៅទៅលើអ្នកដែលមានជំនាញខាងរៀបចំប្រព័ន្ធអគ្គិសនីនៅតាមផ្ទះ រោងចក្រ និងក្រុមហ៊ុនជាដើម។ អ្នកទាំងនោះធ្វើការរៀបចំ ដំឡើង និងថែទាំប្រព័ន្ធខ្សែភ្លើង ហ៊ុយហ្ស៊ីប និងផ្នែកផ្សេងទៀតនៃប្រព័ន្ធចែកចាយអគ្គិសនី។

## ការងារ

- ដំឡើង ធ្វើតេស្តសាកល្បង ថែទាំ និងជួសជុលប្រព័ន្ធខ្សែភ្លើង និងប្រព័ន្ធម៉ាស៊ីនត្រជាក់
- ដំឡើងប្រព័ន្ធទូរស័ព្ទ បណ្តាញទូរគមនាគមន៍ និងកណ្តឹងប្រកាសអាសន្នអគ្គិភ័យ និងប្រព័ន្ធសុវត្ថិភាព
- ជួសជុល ឬផ្លាស់ប្តូរប្រព័ន្ធ និងឧបករណ៍អគ្គិសនី
- ធ្វើការតភ្ជាប់ខ្សែភ្លើងទៅនឹងកុងតាក់ ប្រដាប់ទប់ភ្លើង ប្រដាប់ស៊ក បន្តចរន្តអគ្គិសនី ឬសម្ភារអគ្គិសនីដទៃទៀត
- បង្កើត និងរៀបចំប្លង់ប្រព័ន្ធអគ្គិសនីសម្រាប់គេហដ្ឋាន រោងចក្រ និងក្រុមហ៊ុន
- ធ្វើការត្រួតពិនិត្យជាប្រចាំដើម្បីធានាថាឧបករណ៍ដែលបានដាក់ឲ្យប្រើប្រាស់មានដំណើរការល្អ និងធ្វើការជួសជុលមុនមានការខូចខាតដោយថាហេតុ
- ផ្តល់យោបល់ជូនអ្នកគ្រប់គ្រងអំពីការប្រើប្រាស់ឧបករណ៍ដែលអាចប្រឈមនឹងគ្រោះថ្នាក់។



## ការអប់រំ និងការបណ្តុះបណ្តាល



- បរិញ្ញាបត្ររងផ្នែកអគ្គិសនី
- ការបណ្តុះបណ្តាលរយៈពេលវែងតាមរយៈការអនុវត្តន៍ការងារដោយផ្ទាល់
- មានបទពិសោធន៍ការងារពាក់ព័ន្ធ។

## ជំនាញ និងសមត្ថភាព



- អាចប្រើប្រាស់នូវឧបករណ៍ប្រើដោយដៃដូចជា ទួរណឺវីស ដង្កាប់ កាំបិតរណាអាដែក និងឧបករណ៍ដែលប្រើដោយថាមពលអគ្គិសនី រួមមាន ម៉ូទ័រខួង ឬស្វាន រណា អំពូល ម៉ែត វ៉ុលត៍ម៉ែត និងឧបករណ៍សាក ចរន្តអគ្គិសនីដទៃទៀត
- មានចំណេះដឹងក្នុងការវាស់ស្ទង់ឡើងបំពង់ស្រោបខ្សែភ្លើង និងសាកខ្សែភ្លើង ប្រីភ្លើង និងកុងតាក់
- មានទេពកោសល្យក្នុងការប្រើប្រាស់ដៃបំពេញការងារ
- មានជំនាញទំនាក់ទំនងល្អ
- មានលទ្ធភាពក្នុងការនិយាយ និងយល់ភាសាអង់គ្លេសបានខ្លះៗ ។

## កាយសម្បទា និងបុគ្គលិកលក្ខណៈ

- មានកាយសម្បទាមាំមួន
- មានទំនួលខុសត្រូវខ្ពស់ និងចេះលើកទឹកចិត្តខ្លួនឯង
- មានភាពឧស្សាហ៍ព្យាយាមក្នុងការបំពេញការងារ និងមានភាពអំណត់។

សុពលភាព: 2011-2012

តទៅទំព័របន្ទាប់

ទីភ្នាក់ងារជាតិមុខរបរ និងការងារ

Top Ten Occupation 6.

# អ្នកជំនាញផ្នែកលក់ និងទីផ្សារ

## Sale and Marketing Professional

**អ្នកជំនាញផ្នែកលក់ និងទីផ្សារ** គឺជាអ្នករៀបចំផែនការអភិវឌ្ឍ សម្រប សម្រួល និងអនុវត្តកម្មវិធីផ្សព្វផ្សាយព័ត៌មានក្នុងគោលបំណងលើក កម្ពស់កិត្តិយសក្រុមហ៊ុន ទំនិញ និងសេវាកម្ម និងជាអ្នកតំណាង របស់ក្រុមហ៊ុនក្នុងការលក់ឧបករណ៍បច្ចេកទេស ឧស្សាហកម្ម វេជ្ជ-សាស្ត្រ ឱសថសាស្ត្រ និងបច្ចេកវិទ្យាព័ត៌មាន។

### ការងារ

- ធ្វើការស្រាវជ្រាវទីផ្សារ វិភាគទិន្នន័យដែលប្រមូលបាន រៀបចំផែនការផ្សព្វផ្សាយទីផ្សារ កំណត់អំពីស្ថានភាពទីផ្សារសម្រាប់ផលិតផលថ្មី និងផលិតផលដែលមានស្រាប់ និងសេវាកម្ម
- គាំទ្រដល់ការលូតលាស់ និងការអភិវឌ្ឍអាជីវកម្ម តាមរយៈការរៀបចំ និងការអនុវត្តនូវគោលដៅទីផ្សារដែលបានគ្រោងទុក គោលនយោបាយ និងកម្មវិធីផ្សេងៗ
- ធ្វើផែនការ និងរៀបចំយុទ្ធនាការផ្សព្វផ្សាយពាណិជ្ជកម្ម
- វាយតម្លៃ និងជ្រើសរើសសម្ភារដែលផ្តល់ដោយអ្នកនិពន្ធ អ្នកថតរូប វិចិត្រករ និងអ្នកជំនាញផ្សេងទៀត ដើម្បីធ្វើស្ពតផ្សព្វ-ផ្សាយពាណិជ្ជកម្ម



- មានការយល់ដឹង និងស្វែងយល់ដឹងពីនិយោជក និងអំពីទំនិញ ឬសេវាកម្មរបស់ដៃគូប្រកួតប្រជែង និងស្ថានភាពទីផ្សារ
- ធ្វើការប៉ាន់ប្រមាណអំពីតម្រូវការរបស់អតិថិជន ពន្យល់ និងបង្ហាញអំពីផលិតផល និងសេវាកម្មដល់អ្នកទាំងនោះ



- ផ្តល់យោបល់ពាក់ព័ន្ធទៅនឹងផ្នែកទីផ្សាររួមមានផលិតផលចំរុះ តម្លៃការផ្សព្វ-ផ្សាយពាណិជ្ជកម្ម ការលក់ និងបណ្តាញចែកចាយជាដើម ។

### ការអប់រំ និងការបណ្តុះបណ្តាល

- បរិញ្ញាបត្រផ្នែកទីផ្សារ និងសញ្ញាបត្រដែលមានតម្លៃស្មើ
- វិញ្ញាបនបត្របណ្តុះបណ្តាលជំនាញផ្នែកលក់ និងទីផ្សារ
- មានបទពិសោធន៍ការងារពាក់ព័ន្ធ
